# Community-Based
# Disaster Risk Reduction Programme in Cambodia

កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយថ្នាក់សហគមន៍នៅប្រទេសកម្ពុជា



Oxfam
International

*“Oxfam is working to build a wider institutional culture for disaster management, community preparedness and disaster response. With key emphasis on capacity building and community participation, the programme includes disaster preparedness and response training at community and institutional levels, as well as mitigation activities to limit the effects of drought and flood on food security. The programme has also established effective working relations with a number of different organisations including government bodies, local and international NGOs.”*

*“អង្គការអុកហ្វាម (Oxfam) កំពុងធ្វើការដើម្បីកសាងវប្បធម សំរាប់ការគ្រប់គ្រង គ្រោះមហន្តរាយ ការប្រុងប្រៀបរបស់សហគមន និងការឆ្លើយតបចំពោះគ្រោះមហន្តរាយ។ ជាមួយការកត់សម្គាល់ ដ៏សំខាន់លើការកសាងសមត្ថភាព និងការចូលរួមរបស់សហគមន៏ កម្មវិធ រួមមាន ការបណ្តុះបណ្តាល ស្តីពី ការប្រុងប្រៀបរៀបចំ និងការឆ្លើយតបចំពោះគ្រោះមហន្តរាយ នៅថ្នាក់សហគមន៏ និង ថ្នាក់ស្ថាប័ន ក៏ដូចជាសកម្មភាព កាត់បន្ថយនានា នឹងកំណត់នូវផលប៉ះពាល់នៃគ្រោះរាំងស្ងួត និងទឹកជិនន់ លើសុវត្ថិភាពស្បៀង។ កម្មវិធីនេះ ក៏បាន បង្កើតឡើងផងដែរ នូវទំនាក់ទំនងការងារប្រកបដោយប្រសិទ្ធិភាព ជាមួយអង្គការផ្សេងៗមួយចំនួន រួមមានស្ថាប័ន រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និង អន្តរជាតិ។ ”*



# Acknowledgement

We would like to give special thanks to the Royal Cambodian Govenrment, the National Committee for Disaster Management as well as its Provincial and District agencies, and to our implementing partner NGOs Chamroen Chiet Khmer (CCK), Kratie Women's Welfare Association (KWWA), National Prosperity Association (NAPA), and Partnership for Development in Kampuchea (PADEK).

# Content

Oxfam's Disaster Prevention in Cambodia 1
- Disaster Risk Reduction programme 2

Disasters Affecting Cambodia 3
- Irregular Disasters Caused by Climate Change 5
- Change Affecting Agriculture 7
- Livelihoods and Natural Disasters 8

Pilot Project : Takéo Province 10
- Cambodia, a Land of many Widows 11
- Pilot Project : Takéo Province 13
- Working in the Most Affected Districts 15
- How community-based disaster management was implemented in Takéo 16
- What the Community Wanted 17
- Total Distribution 2003 – 2006 19

The Community: A Pillar of Strength 20
- How We Work 21
- How CBDRM is Implemented in Takéo 23
- Accountability to Beneficiaries, Stakeholders and Donors 24

Gender Equality and Disaster Preparedness 27

Scaling Up 30
- Not Giving Up on Dry Land 31
- Approach and Rationale 34
- Drought Programme 35
- Flood Programme 38

Future Plans 38

A Brief History of Oxfam International in Cambodia 39

Oxfam affiliates and partners working in DRR in Cambodia 40

Written by: Tul Pinkaew, Amy Glass
Edited by: Amy Glass
Designed by: Dow Punpiputt
Photo credits: Jim Holmes/Oxfam (P.5,7,8,10,18,20,27,28,36,37,38), Tul Pinkaew (Cover page, P.11,12,16,17, 32), Howard Davies/Oxfam (P.8,29,37), Gavirel Langford (P.28,29), HANet (P.26)

# Oxfam's Disaster Prevention in Cambodia

## កម្មវិធីការពារគ្រោះមហន្តរាយរបស់អង្គការអុកស្វាម នៅប្រទេសកម្ពុជា

Cambodia remains one of the poorest countries in the world and is faced with numerous challenges in financing, implementing its development, disaster prevention and mitigation. Due to its geographical location Cambodia is one of the most disaster-prone countries in Southeast Asia. Natural disasters such as floods along the Mekong River basin caused by monsoon and paddy fields damage by drought have always had a role in shaping the livelihood of millions in the country.

In 1997 the European Commission's Humanitarian Aid Office Programme for Disaster Prevention, Mitigation and Preparedness (DIPECHO) published a diagnostic for Cambodia recommending that the promotion of community-based approaches to risk reduction as an effective solution to managing disasters.

Rural communities in Cambodia have been coping with disasters in their own ways for centuries and strengthening those traditional coping mechanisms is an efficient and effective way of mitigating risks and improving disaster preparedness.

Oxfam, an international NGO with a mission to serve families in the poorest communities, is both a relief and development agency. Oxfam is committed to addressing the underlying causes and effects of poverty and vulnerability and, therefore within its emergency mandate, is committed to disaster preparedness and mitigation.

ប្រទេសកម្ពុជានៅតែជាប្រទេសមួយក្នុងចំណោមប្រទេសក្រីក្រដ៏ទៃទៀត នៅក្នុងពិភពលោក និងមានការ ប្រឈមមុខជាមួយប្រកួតប្រជែងដ៏ច្រើន នៅក្នុងហិរញ្ញប្បទាន ប្រតិបត្តិការអភិវឌ្ឍន៍របស់ខ្លួន ការការពារ និង ការកាត់បន្ថយគ្រោះមហន្តរាយ ។ ដោយសារតែទីតាំងភូមិសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជា គឺជាប្រទេសមួយ ក្នុងចំណោមប្រទេសដ៏ទៃទៀត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលងាយជួបគ្រោះមហន្តរាយច្រើនបំផុត ។ គ្រោះមហន្តរាយធម្មជាតិ ដូចជាទឹកជំនន់តាមបណ្តោយអាងទន្លេមេគង្គ ដែលបណ្តាលដោយខ្យល់មូសុង និងការខូចខាតវាលស្រែ ដោយសារគ្រោះរាំងស្ងួត តែងតែមានតួនាទីក្នុងការធ្វើឱ្យប៉ះពាល់ ដល់ការរស់នៅរបស់ប្រជាជនរាប់លាននាក់ នៅក្នុងប្រទេសនេះ ។

នៅឆ្នាំ ១៩៩៧ កម្មវិធីការិយាល័យជំនួយមនុស្សធម៌សំរាប់ការការពារគ្រោះមហន្តរាយ របស់គណៈកម្មការ សហគមន៍អ៊ឺរ៉ុប ដែលមានឈ្មោះថា កម្មវិធីកាត់បន្ថយ និង ការការពារ (DIPECHO) បានចេញផ្សាយនូវលទ្ធផលវិភាគមួយសំរាប់ប្រទេសកម្ពុជាដោយបានផ្តល់អនុសាសន៍ថា ការលើកស្ទួយនូវការជួយគាំទ្រ ថ្នាក់មូលដ្ឋានសំរាប់ការកាត់បន្ថយគ្រោះថ្នាក់គឺជាដំណោះស្រាយដ៏មានប្រសិទ្ធិភាពមួយ សំរាប់ការគ្រប់គ្រង នូវគ្រោះមហន្តរាយ ។

សហគមន៍ជនបទនៅប្រទេសកម្ពុជាបាននិងកំពុងជួបប្រទះគ្រោះមហន្តរាយ នៅក្នុងជីវភាពរស់នៅផ្ទាល់របស់ពួកគេរាប់សតវត្សរ៍មកហើយ និង ការពង្រឹងនូវយន្តការការពារតាមបែបប្រពៃណី គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធិភាព និង សុពលភាពមួយ ដល់ការការកាត់បន្ថយគ្រោះថ្នាក់នានា និងដល់ការធ្វើឱ្យប្រសើរឡើង នូវការការពារគ្រោះមហន្តរាយ ។

អុកស្វាម ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ មានបេសកកម្មដើម្បីបំរើគ្រួសារទាំងឡាយក្នុង សហគមន៍ក្រីក្របំផុត គឺជាភ្នាក់ងារទាំងផ្នែកសង្គ្រោះ និងអភិវឌ្ឍន៍។ អុកស្វាម ប្តេជ្ញារកឱ្យឃើញ នូវបុព្វហេតុសំខាន់ៗ និងផលប៉ះពាល់នៃភាពក្រីក្រ និងភាពងាយរងគ្រោះ ហើយ ហេតុដូច្នេះនៅក្នុងអាណត្តិបន្ទាន់របស់ខ្លួន អុកស្វាមបានប្តេជ្ញាចំពោះការការពារនិងការកាត់បន្ថយគ្រោះមហន្តរាយ ។

# Disaster Risk Reduction programme

## កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយ

Oxfam is working to build a wider institutional culture for disaster management, community preparedness and disaster response. The key emphasis is on capacity building and community participation, disaster preparedness and response training at community and institutional levels, and mitigation activities to limit the effects of drought and flood on food security.

In June 1999 the Oxfam International alliance made up of eight Oxfam affiliates implemented a Disaster Risk Reduction programme in Cambodia. The purpose was to develop the organisation's emergency preparedness and response as well as support local stakeholders in responding to emergencies and natural disasters at the national level.

The programme started its first project in 2003 in Takéo province with the emphasis on community-based disaster preparedness and mitigation.

### Oxfam's approach aims to:

- Enhance the capacity of Cambodian NGOs to respond to emergencies
- Promote village emergency preparedness;
- Strengthen livelihoods of those most vulnerable in each community to improve their resilience to disaster
- Monitor emergencies through communication and networking
- Increase institutional understanding of Disaster Risk Reduction through Cambodia's National Committee for Disaster Management (NCDM).

អង្គការអុកស្វាម  កំពុងធ្វើការដើម្បីកសាងវប្បធម៌ចាត់តាំងដ៏ទូលំទូលាយមួយសំរាប់ការគ្រប់គ្រងគ្រោះមហន្តរាយ  ការត្រៀមបង្ការ  និងការឆ្លើយតបចំពោះគ្រោះមន្តរាយ  របស់សហគមន៍ ។ កំណត់សម្គាល់ដ៏សំខាន់គឺលើការកសាងសមត្ថភាពនិងការចូលរួមរបស់សហគមន៍ ការបណ្តុះបណ្តាលស្តីពីការការពារនិងការឆ្លើយតបចំពោះគ្រោះមហន្តរាយនៅកំរិតសហគមន៍ និងស្ថាប័ន និងសកម្មភាពកាត់បន្ថយនានា ដើម្បីកំណត់នូវផលប៉ះពាល់នៃគ្រោះរាំងស្ងួត  និងទឹកជំនន់  លើសុវត្ថិភាពស្បៀង  ។

នៅខែមិថុនា  ឆ្នាំ  ១៩៩៩  សម្ព័ន្ធភាពអន្តរជាតិអុកស្វាមដែលបានប្រសូត្រឡើងពីការចូលរួមគ្នានៃអុកស្វាមប្រាំបី  បានប្រតិបត្តិការនូវកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយមួយនៅប្រទេសកម្ពុជា ។ គោលបំណងគឺដើម្បីអភិវឌ្ឍនូវការប្រុងប្រៀបរៀបចំនិងការឆ្លើយតបចំពោះគ្រោះអាសន្នរបស់អង្គការក៏ដូចជាការគាំទ្រចំពោះអង្គការក្នុងស្រុកនានា  ក្នុងការឆ្លើយតបចំពោះភាពអាសន្ននិងគ្រោះធម្មជាតិនានានៅថ្នាក់ជាតិ  ។

កម្មវិធីនេះបានចាប់ផ្តើមនូវគំរោងដំបូងរបស់ខ្លួននៅឆ្នាំ  ២០០៣  នៅខេត្តតាកែវ  ជាមួយការផ្តោតអារម្មណ៍ទៅលើការការពារនិងការកាត់បន្ថយគ្រោះមហន្តរាយថ្នាក់សហគមន៍  ។

### ការជួយគាំទ្ររបស់អង្គការអុកស្វាម  មានគោលបំណងដើម្បី  :

* លើកកំពស់សមត្ថភាពអង្គការក្រៅរដ្ឋាភិបាលកម្ពុជា  ដើម្បីឆ្លើយតបចំពោះគ្រោះអាសន្ននានា
* លើកស្ទួយនូវការការពារភាពអាសន្នថ្នាក់ភូមិ
* ពង្រឹងនូវការរស់នៅរបស់ប្រជាពលរដ្ឋដែលងាយរងគ្រោះទាំងនោះនៅក្នុងសហគមន៍និមួយៗ  ដើម្បីកែលំអនូវភាពធូរស្បើយឡើងវិញរបស់ពួកគេពីគ្រោះមហន្តរាយ
* តាមដានគ្រោះអាសន្នតាមរយៈសហគមន៍  និងការបង្កើតបណ្តាញ
* បង្កើននូវការយល់ដឹងតាមបែបចាត់តាំងស្តីពីកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយតាមរយៈគណៈកម្មាធិការជាតិ  គ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា  (NCDM)

# Disasters Affecting Cambodia

## គ្រោះមហន្តរាយធ្វើឱ្យប៉ះពាល់ដល់កម្ពុជា

*population affected by drought **




*population affected by flood **




## Drought:

The monsoon rainfall pattern consists of two peaks with a series of irregular dry patches, which may last for three weeks or more. Dry patches during wet season are known as drought. Crops can suffer from these droughts if no source of supplementary irrigation is available. In recent years, Cambodia has suffered from prolonged drought lasting more than a month caused by an imbalance in the distribution monsoon rainfall.

### គ្រោះរាំងស្ងួត:

លំនាំភ្លៀងខ្យល់មូសុង មានពីរចំណុចធំៗ ដែលអមដោយក្រុមកួនរដូវប្រាំងខុសធម្មតាមួយក្រុមដែលអាចមានរយៈពេល ៣ សប្តាហ៍ ឬច្រើនជាងនេះ ។ កួនរដូវប្រាំងក្នុងកំឡុងរដូវវស្សាត្រូវបានគេស្គាល់ថាជារដូវរាំងស្ងួត ។ ប្រសិនបើមិនមានប្រភពធារាសាស្ត្រផ្គត់ផ្គង់ណាមួយទេនោះ ដំណាំអាចទទួលរងការខូចដោយសារកួនរដូវប្រាំងទាំងនេះ។ ប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាបានទទួលរងគ្រោះដោយសារតែគ្រោះរាំងស្ងួត ដែលអូសបន្លាយពេលយូរជាង ១ ខែ បណ្តាលដោយអតុល្យភាពនៅក្នុងការចែកចាយទឹកភ្លៀងខ្យល់មូសុង ។

* Source : NCDM, August 2002

## Flooding

Flooding is both an important aspect of agricultural production and also the source of great devastation. Every year the Mekong River rises as a result of heavy rains in the Upper Mekong region. The river overflows into the Tonle Sap Lake, increasing its surface area to four times its normal size, which directly floods the surrounding provinces. The Mekong River also floods its banks routinely during the wet season, covering the land on each side of the river in up to four metres of water.

### ការជន់លិច:

ការជន់លិចគឺជាកត្តាដ៏សំខាន់មួយ ទាំងសំរាប់ផលិតកម្មកសិកម្ម និងក៏ដូចជាប្រភពនៃការបំផ្លិចបំផ្លាញដ៏សម្បើមផងដែរ ។ រៀងរាល់ឆ្នាំ ទន្លេមេគង្គតែងតែឡើងដោយសារតែលទ្ធផលនៃទឹកភ្លៀងដ៏ច្រើនសន្ធឹកសន្ធាប់នៅតំបន់ទន្លេមេគង្គប៉ែកខាងលើ ។ ទន្លេនេះហូរចាក់ចូលមកទន្លេសាបដោយកើនឡើងរហូតដល់បួនដងនៃបរិមាណទឹកធម្មតារបស់ខ្លួន ដែលបង្កើតឱ្យមានទឹកជំនន់ដល់ខេត្តនានានៅជុំវិញដោយផ្ទាល់ ។ ទន្លេមេគង្គក៏តែងតែជន់លិចច្រាំងរបស់ខ្លួនជាញឹកញាប់ផងដែរក្នុងកំឡុងរដូវវស្សាដោយគ្របដណ្តប់លើផ្ទៃដីនៅប៉ែកនិមួយៗនៃទន្លេរហូតដល់មានកំពស់ទឹក៤ម៉ែត្រ ។





Flash flooding usually occurs as a result of intense localised rainfall during slow moving storms. Flooding of any kind affects water purity and increases the chances of diseases among people and livestock, as well as destroying crops, homes and buildings.

ការជន់លិចមួយភ្លែតៗជាធម្មតាតែងតែកើតឡើងដោយសារតែលទ្ធផលនៃភ្លៀងធ្លាក់ផ្ទួនៗដ៏ខ្លាំងក្នុងកំឡុងពេលមានព្យុះមានល្បឿនយឺតៗ ។ ការជន់លិចប្រភេទណាមួយក៏ដោយ តែងតែប៉ះពាល់ដល់ភាពស្អាតនៃទឹកនិងបង្កើនឱ្យមានចរន្តជំងឺនានាក្នុងចំណោមប្រជាជន និងសត្វពាហនៈក៏ដូចជាការបំផ្លាញនូវដំណាំ ផ្ទះសម្បែង និង អាគារផងដែរ ។

## Erosion

### ការហូរច្រោះ

Erosion is a secondary effect of flooding and hence is a common problem along the banks of the Mekong and the lower reaches of the Tonle Sap. Land, which has been cleared of riparian vegetation, is especially vulnerable as cleared land is not protected and is therefore easily eroded by the added impact of rainfall.

ការហូរច្រោះគឺជាផលប៉ះពាល់បន្ទាប់បន្សំមួយនៃការជន់លិចហើយហេតុដូច្នេះគឺជាបញ្ហារួមតាមបណ្តោយច្រាំងទន្លេមេគង្គ និងតំបន់ទំនាបនៃទន្លេសាប ។ ដីដែលត្រូវបានគេសំអាតរុក្ខជាតិនានានៅតាមមាត់ទន្លេ ជាពិសេសងាយទទួលផលប៉ះពាល់ ខណៈពេលដីដែលត្រូវបានគេសំអាតមិនមានអ្វីការពារ ហើយហេតុដូច្នេះ ងាយនឹងទទួលរងការហូរច្រោះ ដោយសារតែឥទ្ធិពលផ្ទួនៗនៃការធ្លាក់ទឹកភ្លៀង ។

Erosion causes significant economic losses and exacerbates vulnerability by reducing the fertility of the land, often in prime agricultural areas. Another serious effect of erosion is the siltation of the Tonle Sap, which is becoming increasingly shallow.

ការហូរច្រោះបណ្តាលឱ្យមានការបាត់បង់សេដ្ឋកិច្ចដ៏ខាន់ និងភាពងាយរងគ្រោះដ៏ធ្ងន់ធ្ងរដោយការកាត់បន្ថយជីវជាតិដី ជាញឹកញាប់នៅតំបន់កសិកម្មចម្បងៗ ។ ផលប៉ះពាល់នៃការហូរច្រោះដ៏ធ្ងន់ធ្ងរមួយផ្សេងទៀត គឺការហូរចូលដីល្បាប់ទៅក្នុងទន្លេសាបដែលធ្វើឱ្យកាន់តែរាក់ទៅៗ ។

# Irregular Disasters Caused by Climate Change
## គ្រោះមហន្តរាយដ៏ទៃទៀត បណ្តាលដោយការប្រែប្រួលអាកាសធាតុ

The natural patterns of drought and flood, although unpreventable, have always been relatively predictable. However, during the past two decades, the seasonal cycle has been altered and exacerbated by man-made interventions, from unsustainable logging and large dams construction along the Mekong River.

A SIGNIFICANT SHIFT has now been noted between summer and winter rains, causing problems for farmers. Prolonged dry spells have had a negative effect on agriculture and changed the salinity of watercourses, damaging aquaculture.

During the past decade there seems to be a steady decline in annual rainfall totals, increasing the risk of droughts. At the same time, there have been increased numbers of intense rainstorms.

IN 2000, FLOODING IN CAMBODIA WAS REPORTED TO BE THE WORST IN 40 YEARS. More than 350 people died and 3.2 million were affected. Two years later (2002) a serious drought damaged 62,702 hectares of rice plantations affecting more than 2 million people in eight provinces.

The Asia Conference on Disaster Reduction in February 2004 acknowledged that the rise in average temperatures caused by global-warming, would potentially result in an increasingly short cycle of flood and drought in Cambodia. The current cycle that has persisted since 2000.



| Disaster | Year | Number of People | |
|---|---|---|---|
| | | Killed | Affected |
| Flood | 1991 | 100 | 900,000 |
| Flood | 1994 | 506 | - |
| Famine | 1995 | - | 2,500,000 |
| Flood | 1996 | 59 | 1,310,000 |
| Famine | 1996 | - | 2,500,000 |
| Famine | 1998 | - | 900,000 |
| Flood | 2000 | 347 | 3,448,053 |
| Flood | 2001 | 56 | 1,669,182 |
| Flood | 2002 | 29 | 1,470,000 |
| Drought | 2002 | - | 650,000 |
| Flood | 2005 | 16 | - |
| Drought | 2005 | - | 600,000 |

*EM_DAT[1] Disaster Profile for Cambodia*

តាមលំនាំធម្មជាតិរបស់គ្រោះរាំងស្ងួតនិងទឹកជំនន់ ទោះបីជាមិនអាចការពារបានក៏ដោយ ក៏តែងតែអាចព្យាករណ៍បានដែរ ។ ទោះបីយ៉ាងណាក៏ដោយ ក្នុងកំឡុងពេលពីរទសវត្សរ៍មកនេះ ការរយៈវេលានៃវដ្ដបានប្រែប្រួល និងកាន់តែធ្ងន់ធ្ងរដោយសារតែទង្វើនានារបស់មនុស្សជាតិ តាមរយៈការកាប់ឈើដោយគ្មាននិរន្តរភាព និងការកសាងទំនប់ធំៗតាមបណ្ដោយទន្លេមេគង្គ។

ឥឡូវនេះ ការប្រែប្រួលដ៏សំខាន់មួយត្រូវបានគេកត់ចំណាំ រវាងភ្លៀងរដូវក្ដៅនិងរដូវរងារ ដោយបណ្ដាលឱ្យមានបញ្ហានានាដល់កសិករ ។ រយៈពេលរាំងស្ងួតដែលបានអូសបន្លាយពេលយូរបានជះឥទ្ធិពលជាអវិជ្ជមានដល់កសិកម្ម និងបានធ្វើឱ្យប្រែប្រួលនូវភាពប្រៃនៃផ្លូវទឹកនានា ដោយការបំផ្លាញនូវជលវប្បកម្ម ។

ក្នុងកំឡុងទសវត្សរ៍កន្លងមកនេះ ទំនងដូចជាមានការថយចុះជាប្រចាំនូវចំនួនសរុបនៃទឹកភ្លៀងប្រចាំឆ្នាំ ដោយកើនឡើងនូវគ្រោះរាំងស្ងួតទៅវិញ ។ ជាមួយគ្នានេះដែរក៏មានការកើនឡើងនូវព្យុះភ្លៀងដ៏ធំធរមួយចំនួន ។

នៅឆ្នាំ ២០០០ ការជន់លិចនៅ ក្នុងប្រទេសកម្ពុជា ត្រូវបានគេរាយការណ៍ថា មានសភាពអាក្រក់ជាង ៤០ឆ្នាំ កន្លងមក ។ ប្រជាជនជាង ៣៥០ នាក់បានស្លាប់ និង ៣.២ លាននាក់បានទទួលរងផលប៉ះពាល់ ។ ពីរឆ្នាំក្រោយមកទៀត (២០០២) គ្រោះរាំងស្ងួតដ៏ធ្ងន់ធ្ងរមួយ បានបំផ្លាញនូវដីស្រែចំនួន ៦២.៧០២ ហិចតា ដោយប៉ះពាល់ប្រជាជនចំនួនជាង ២លាននាក់នៅក្នុងខេត្តចំនួន៨ ។

នៅក្នុងខែកុម្ភៈ ឆ្នាំ ២០០៤ សន្និសិទ្ធអាស៊ីស្ដីពីការកាត់បន្ថយគ្រោះមហន្តរាយបានទទួលស្គាល់ថា ការកើនឡើងនៅស៊ីតុណ្ហភាពជាមធ្យម ដែលបណ្ដាលដោយកំដៅផែនដី នឹងបណ្ដាលឱ្យរយៈវេលានៃគ្រោះទឹកជំនន់និងរាំងស្ងួត កាន់តែខ្លីទៅៗប្រកបដោយសក្ដានុពលនៅក្នុងប្រទេសកម្ពុជា ។ រយៈវេលាបច្ចុប្បន្ននេះមានមកតាំងពីឆ្នាំ ២០០០ ។



- Normal flood year in the past, water level: **2 meters**
- Big/Serious floods 1961, 1966, 1996, 2000 and 2001: water level **7 meters or higher**
- Since 2001, water level during seasonal flooding in some areas still as high as **4 -5 meters**
- Prolonged drought was experienced in 1997 to 1998 and consecutive drought in 2001, 2002, 2004, 2005 and 2006

*Oxfam and Cambodia's National Committee for Disaster Management (NCDM)

# Change Affecting Agriculture
## ការប្រែប្រួលប៉ះពាល់ដល់កសិកម្ម

The Cambodian climate is governed by two seasons, dry and wet. People living in non-flooded areas cultivate rice during the wet season from May–October when there is substantial amount of rain. Those living in the flooded basins, in turn, cultivate rice during dry season in the months after the flood had resided.

The seasonal shift, however, has caused irregularly dry patches during the wet season occurring over long periods of time. When there is no rain for 20 days or more before, during and after the planting season, the paddy fields dry out and without proper irrigation the rice plants die.

Flooding of the Mekong has become increasingly dramatic in recent years. The floods are more prolonged in many parts of the country which remain submerged under water for as much as six months. Schools are closed and people cannot grow crops and have to resort to fishing as an alternative.

អាកាសធាតុកម្ពុជា គ្រប់គ្រងដោយរដូវពីរគឺរដូវប្រាំងនិងរដូវវស្សា ។ ប្រជាជនដែលរស់នៅតាមតំបន់ដែលគ្មានទឹកជំនន់ដាំដុះស្រូវ ក្នុងកំឡុងរដូវវស្សាចាប់ពីខែឧសភាដល់តុលា ខណៈពេលដែលមានទឹកភ្លៀងគ្រប់គ្រាន់ ។ ផ្ទុយទៅវិញ អ្នកដែលរស់នៅតាមទន្លេដែលមានទឹកជំនន់ តែងតែដាំដុះស្រូវក្នុងកំឡុងរដូវប្រាំងនៅខែបន្ទាប់ពីមានទឹកជំនន់ ។

ទោះបីយ៉ាងណាក៏ដោយ ការប្រែប្រួលរដូវបានបណ្តាលឱ្យមានកូនរដូវប្រាំងមិនទៀងទាត់តូចៗក្នុងកំឡុងរដូវវស្សាដោយកើតឡើងមានរយៈពេលវែង ។ ខណៈពេលដែលមិនមានភ្លៀងរយៈពេល ២០ ថ្ងៃ ឬច្រើនជាងនេះក្នុងកំឡុងនិងក្រោយពីរដូវដាំដុះ វាលស្រែ ហួតហែង និងដោយគ្មានធារាសាស្ត្រសមរម្យ ដើមស្រូវនានានឹងត្រូវងាប់។

ការជន់លិចរបស់ទន្លេមេគង្គកាន់តែកើតឡើងច្រើនទៅៗនៅប៉ុន្មានឆ្នាំថ្មីៗនេះ ។ ទឹកជំនន់កាន់តែអូសបន្លាយពេលយូរ នៅផ្នែកជាច្រើននៃប្រទេសដែលនៅតែជន់លិចច្រើនជាង៦ខែ ។ សាលារៀនត្រូវបានបិទទ្វារ និងប្រជាជន មិនអាចបង្កបង្កើនផលបាន ហើយត្រូវតែធ្វើការនេសាទដែលជាជីវីសមួយផ្សេងទៀត ។





## Drought Area Case Study

## ការសិក្សានៅតំបន់គ្រោះរាំងស្ងួត

An Oxfam study of the relationship between climate and agriculture yield over the past ten years (1996 – 2006) in the drought prone area of Romeas Hek District, Svay Rieng Province has shown that since 1998 every year has been a drought year, with the exception of 2003. In the past, the drought cycle lasted anywhere from three to twelve years. As a result, rice production has significantly decreased from 1300-1400 kilogrammes of rice per hectare per yield to only 200 – 700 kilogrammes. This is not enough for a family to live on let alone sell.

ការសិក្សាមួយរបស់អង្គការអុកស្វាមស្តីពីទំនាក់ទំនងរវាងអាកាសធាតុនិងផលកសិកម្មជាងដប់ឆ្នាំកន្លងមកនេះ (១៩៩៦-២០០៦) នៅក្នុងតំបន់ដែលពោរពេញដោយគ្រោះរាំងស្ងួតរបស់ស្រុករមាសហែក ខេត្តស្វាយរៀង បានបង្ហាញថា ចាប់តាំងពីឆ្នាំ១៩៩៨មក រៀងរាល់ឆ្នាំគឺជាឆ្នាំដែលរាំងស្ងួតលើកលែងតែឆ្នាំ២០០៣ចេញ ។ ពេលកន្លងមក រយៈវេលារាំងស្ងួត បានអូសបន្លាយពេលគ្រប់កន្លែងពី៣ឆ្នាំទៅ១២ឆ្នាំ ។ ជាលទ្ធផលផលិតកម្មស្រូវបានធ្លាក់ចុះជាគំហុក ពី ១៣០០-១៤០០ គ.ក ស្រូវក្នុង ១ ហ.ត មកនៅត្រឹម ២០០-៧០០ គ.ក ។ ចំនួននេះវាមិនគ្រប់គ្រាន់សំរាប់គ្រួសារមួយដើម្បីបន្តរស់បានទេ ។

# Livelihoods and Natural Disasters

ការរស់នៅ និង គ្រោះធម្មជាតិនានា

## People Rely On Agriculture

## ប្រជាជនពឹកផ្អែកលើកសិកម្ម

Agriculture plays the most important role in the economy and society of Cambodia. It accounts for about 45% of the country's GDP and 70% of its labour force. Over 85% of the population live in the countryside. Though Cambodia's natural conditions allow for year-round cultivation of many kinds of crops, rice production accounts for 89% of agricultural undertakings. Traditionally, a single rain-fed crop is planted per year.

កសិកម្មដើរតួនាទីដ៏សំខាន់បំផុតនៅក្នុងសេដ្ឋកិច្ចនិងសង្គមរបស់ប្រទេសកម្ពុជា ។ វាទទួលខុសត្រូវប្រហែល ៤៥ ភាគរយ នៃ GDP របស់ប្រទេស និង ៧០ ភាគរយនៃកម្លាំងពលកម្មរបស់ខ្លួន ។ ជាង ៨៥ ភាគរយនៃប្រជាជនរស់នៅទីជនបទ ។ ទោះបីលក្ខខណ្ឌធម្មជាតិរបស់ប្រទេសកម្ពុជាអនុញ្ញាតិឱ្យមានការដាំដុះដំណាំគ្រប់ប្រភេទពេញមួយឆ្នាំក៏ដោយ ក៏ផលិតកម្មស្រូវទទួលខុសត្រូវបាន ៨០ភាគរយ នៃការងារកសិកម្ម។ ជាប្រពៃណី ប្រភេទដំណាំដែលអាចរស់បានដោយសារទឹកភ្លៀងតែមួយមុខត្រូវបានគេដាំក្នុង ១ ឆ្នាំម្តង ។






Because of the fertility of the soil, the areas around the Tonle Sap (literally translated as the ‘fresh water lake’) and along the Mekong River are considered the country’s rice baskets. Rice production, however, remains family-based subsistence farming, relying principally on family labour and, as such has low capital and technological inputs. The average landholding per farmer is estimated at 2-3 hectares, with 70% used for wet-rice cultivation. In addition to low access to fertiliser and appropriate seeds, water shortage, and innovative technologies, the smallness of the paddy size accounts partly for the relatively low average yield of 1-1.5 tons per hectare. In managed conditions, the average yield can reach 3 tons per hectare.

## Poverty and Vulnerability to Disasters

Cambodia’s high level of poverty compounds the risks for the most vulnerable. Few can afford to build up reserves of food, cash savings and other coping mitigation mechanisms.

High levels of debt, most often incurred to meet health emergencies, reduce the ability to mobilise during a disaster, and recover afterwards. Interest rates are high and relief measures are sometimes diverted to pay creditors.

Poverty is also a source of malnutrition. People suffering from malnutrition often do not have the physical reserves of strength or immunity to cope with the secondary effects of water-borne diseases.

ដោយសារតែភាពសំបូរជីវជាតិនៃដីតំបន់នានានៅជុំវិញទន្លេសាប តាមន័យនៃពាក្យត្រូវបានគេបកប្រែថាជា និងតាមបណ្តោយទន្លេគេង្គត្រូវបានគេចាត់ទុកថាជាជង្រុកស្រូវរបស់ប្រទេស ។ ទោះយ៉ាងណាក៏ដោយ ផលិតកម្មស្រូវនៅតែជារបរកសិកម្មលក្ខណៈគ្រួសារ ដោយពឹកផ្អែកជាគោលការណ៍តែលើកម្លាំងពលកម្មគ្រួសារ ហើយហេតុដូច្នេះ មានផលទុន និង ទិន្នផលបែបបច្ចេកវិទ្យាទាប ។ ការគ្រប់គ្រងដីជាមធ្យមក្នុងកសិករម្នាក់ មានប្រមាណ ២-៣ ហ.ត ដោយមាន ៧០ ភាគរយ ត្រូវបានប្រើប្រាស់ដើម្បីការដាំដុះស្រូវរដូវវស្សា ។ បន្ថែមពីលើការទទួលបានដីតិចតួចនូវជីរ និងពូជស្រូវដ៏សមស្រប ការខ្វះទឹក និង បច្ចេកវិទ្យាបែបឆ្នៃប្រឌិត ចំនួនតិចតួចនៃទំហំដីស្រែ ជាផ្នែកមួយបណ្តាលឱ្យមានទិន្នផលជាមធ្យមទាបដោយទទួលបានប្រមាណ ១-១.៥ តោន ក្នុង ១ ហ.ត ។ យោងទៅតាមលក្ខខណ្ឌដែលទទួលការគ្រប់គ្រងនានា ដីស្រែជាមធ្យមអាចទទួលបាន ៣ តោនក្នុង ១ ហ.ត ។

## ភាពក្រីក្រ និង ភាពងាយរងគ្រោះចំពោះគ្រោះមហន្តរាយ

កំរិតដ៏ខ្ពស់នៃភាពក្រីក្ររបស់ប្រទេសកម្ពុជាបង្កើតឱ្យមានគ្រោះថ្នាក់សំរាប់អ្នកដែលងាយរងគ្រោះបំផុត ។ មនុស្សមួយចំនួនអាចលៃលករក្សាស្បៀងសន្សំប្រាក់ និងកសាងយន្តការកាត់បន្ថយគ្រោះថ្នាក់ដ៏ទៃទៀត ។

កំរិតខ្ពស់នៃបំណុល ជាញឹកញាប់ត្រូវបានគេបុលដើម្បីឆ្លើយតបចំពោះភាពបន្ទាន់ផ្នែកសុខភាព កាត់បន្ថយនូវលទ្ធភាពប្រើប្រាស់ ក្នុងកំឡុងពេលមានគ្រោះមហន្តរាយ និង ការធ្វើឱ្យធូរស្បើយឡើងវិញជាបន្តបន្ទាប់ ។ អត្រាការប្រាក់ខ្ពស់និងសំពាធសង្គ្រោះ ពេលខ្លះត្រូវបានគេបំលែងដើម្បីសងម្ចាស់បំណុល ។

ភាពក្រីក្រក៏ជាប្រភពនៃការខ្វះអាហារូបត្ថម្ភផងដែរ ។ ប្រជាជនដែលរងគ្រោះដោយសារការខ្វះអាហារូបត្ថម្ភ ជាញឹកញាប់មិនមានកម្លាំងពលំមាំមួនឬភាពសាំនានាដើម្បីទប់ទល់ជាមួយផលប៉ះពាល់បន្ទាប់បន្សំនានាដែលកើតឡើងពីជមីឆ្លងតាមរយៈទឹក ។

# *Pilot Project* : Takéo Province

គំរោងសាកល្បងៈ ខេត្តតាកែវ



# Cambodia, a Land of many Widows

## Oxfam's work improving the lives of those living in Takéo province

## ប្រទេសកម្ពុជា. ទឹកដីដែលមានស្ត្រីមេម៉ាយច្រើន

### ការងាររបស់អង្គការអុកស្វាម គឺការកែលំអជីវិតរស់នៅរបស់អ្នករស់នៅក្នុងខេត្តតាកែវ

Life for Ouch Bopha, a single mother of seven, has always been difficult to predict with any reasonable degree of accuracy. Like many Cambodian women who lost their husbands during the fall out of the Khmer Rouge regime, Mrs Bopha has had to take sole responsibility of her family.

After the fighting stopped in 1998, a large population of men had been killed and thousands of Cambodian women, particularly widows, found themselves as the head of the household, a role which they were traditionally not accustomed to.

Mrs Bopha, 47, was widowed when her husband, a soldier, was killed during fighting in the Khmer Rouge controlled areas. Mrs Bopha and her teenage son, Chea, have had to work the fields and grow rice to keep afloat the family without the support of another adult.

Chey Chok district, in Takéo province, where Mrs Bopha and her children live, is located on the lower Mekong Delta, a usually flooded plain where rice cultivation can only be done within a few months of the year, when the land is not submerged. People resort to fishing and collecting water plants, such as Morning Glory, to make ends meet.

"We (my son and I) do not have a man to help us plow the soil and clear the land in time to plant enough rice for consumption let alone sell during the short period of time," said Mrs Bopha.



"When it floods, I have to spend most of the time taking apart the bamboo floor of my home and raising it to cope with the increasing water level so I have no time to find food or go fishing," said Mrs Bopha.

Mrs Bopha said that in 2000 and 2001 her family could not grow rice at all because of the unprecedented amount of flood, which she said no one had experienced before.

In 2003 Oxfam implemented a community-based disaster risk management programme in 13 of the most remote and vulnerable villages in Takéo province with the aim to minimise the impact of natural disasters on the food security and livelihoods of women and men in these areas.

Through its local partner - Chamroen Chiet Khmer (CCK) – Oxfam provided training and capacity building on flood preparedness, hygiene and gender sensitive issues to a Village Committee for Disaster Management (VCDM) which in turn transfers the information to the community.

The VCDM, through a transparent selection process, also provided boats, fishing nets and repaired homes to those families who needed the assistance most.

Oxfam repaired Mrs Bopha's home as well as raised her homestead to avoid the floods. Her family was also provided a boat and some fishing nets. "Now, I don't have to worry about fixing the house anymore. I have time to fish especially with a boat I can catch more fish to eat as well as sell," she said.

During the floods, Mrs Bopha now also goes out everyday on her boat to collect morning glory to sell across the Vietnamese boarder.

"My son cuts the stems and collects the morning glory while I do the paddling. We have to finish before midday in order to make it cross the Vietnamese border and back before the strong winds come in the evening but it is worth doing it," she said.

Mrs Bopha is able to earn around 20,000 riel or five US dollars by selling the water plant. "The boat has helped the communities tremendously. By selling fish and morning glory alone, people who are part of the programme are earning enough money to finally be able to reclaim their lives," said Un Sokrit, Oxfam's Flood Programme Officer.



ជីវិតរបស់លោកស្រីអួច បុប្ផ ដែលជាមាតាមួយរូបមានកូន ៧ នាក់ តែងតែជួបប្រទះនូវការលំបាក់ជានិច្ចក្នុងការ ប៉ាន់ប្រមាណនូវកំរិតនៃតំរូវការដ៏ជាក់លាក់សមហេតុណាមួយនោះ ។ ដូចស្ត្រីកម្ពុជាជាច្រើនទៀតដែលបានបាត់បង់ប្តីរបស់ខ្លួនក្នុងរបបខ្មែរក្រហម លោកស្រីបុប្ផបានដើរតួនាទីទទួលខុសត្រូវចំពោះគ្រួសាររបស់លោកស្រី ។

បន្ទាប់ពីការវាយប្រយុទ្ធគ្នាត្រូវបានបញ្ចប់នៅឆ្នាំ ១៩៩៨ ចំនួនមនុស្សប្រុសដ៏ច្រើនសន្ធឹកសន្ធាប់ត្រូវបានគេសម្លាប់និង ស្ត្រីកម្ពុជារាប់ពាន់នាក់ជាពិសេសស្ត្រីមេម៉ាយ បានមើលឃើញខ្លួនឯងថាជាមេគ្រួសារ ជាតួនាទីមួយដែលពួកគេមិនធ្លាប់ជួបប្រទះ តាមប្រពៃណីទាល់តែសោះ ។

លោកស្រីបុប្ផដែលមានអាយុ ៤៧ ឆ្នាំ បានធ្លាក់ខ្លួនជាស្ត្រីមេម៉ាយនៅពេលដែលប្តីលោកស្រីជាទាហានមួយរូប ត្រូវបានគេសម្លាប់ក្នុងកំឡុងពេលវាយប្រយុទ្ធគ្នា នៅក្នុងតំបន់នានាដែលគ្រប់គ្រងដោយខ្មែរក្រហម ។ លោកស្រីបុប្ផ និងកូនប្រុសវ័យជំទង់របស់លោកស្រីឈ្មោះ ជា ត្រូវតែធ្វើការនៅវាលស្រែ និងដាំស្រូវ ដើម្បីជួយគ្រួសារ ខណៈពេលដែលមិនមានកូនជំទង់ដ៏ទៃទៀតជួយ ។

ស្រុកជ័យជោគ នៅខេត្តតាកែវ ដែលជាទីកន្លែងលោកស្រីបុប្ផ និងកូនៗរបស់លោកស្រីរស់នៅ មានទីតាំងនៅជីសណ្តូរទំនាបទន្លេមេគង្គជាតំបន់

> "Now, I don't have to worry about fixing the house anymore. I have time to fish especially with a boat I can catch more fish to eat as well as sell,"
>
> "ឥឡូវនេះ ខ្ញុំលែងព្រួយបារម្ភពីការជួសជុលផ្ទះសំបែងតទៅទៀតហើយ ។ ខ្ញុំមានពេលវេលាសំរាប់នេសាទ ជាពិសេសជាមួយនឹងទូកមួយនេះ ខ្ញុំអាចចាប់ត្រីបានកាន់តែច្រើនសំរាប់ហូបក៏ដូចជាលក់ដែរ" ។

ដែលតែងតែទឹកជំនន់ ដែលជាទីកន្លែងអាចធ្វើការសាបព្រោះស្រូវបានតែពីរបីខែក្នុង ១ ឆ្នាំ ខណៈពេលដែលដី មិនទាន់ត្រូវបានជន់លិច ។ ប្រជាជនបែរទៅនេសាទត្រី និងបេះរុក្ខជាតិដែលដុះក្នុងទឹកដូចជា ត្រកួនដើម្បីបំពេញតំរូវការ ។

លោកស្រីបុប្ផ បានមានប្រសាសន៍ថា "យើងខ្ញុំ កូនប្រុសខ្ញុំ និងខ្ញុំ មិនមានមនុស្សប្រុសណាម្នាក់ ដើម្បីជួយភ្ជួររាស់ដី និង សំអាតដីឱ្យទាន់ពេលវេលាដើម្បីដាំស្រូវឱ្យ បានគ្រប់គ្រាន់ សំរាប់ការហូបចុក ក្រៅតែពីខ្លួនឯង ក្នុងកំឡុងរយៈពេលដ៏ខ្លីនេះទេ" ។

លោកស្រីបុប្ផ បានមានប្រសាសន៍ថា "នៅពេលដែលមានទឹកជំនន់ ខ្ញុំត្រូវតែចំណាយពេលវេលាច្រើនបំផុតដើម្បីកាប់ឫស្សីយកមកទប់កំរិតទឹកដែលចេះតែកើនឡើង ដូច្នេះខ្ញុំមិនមានពេលដើម្បីរកស្បៀងឬរកត្រីឡើយ ។"

លោកស្រីបុប្ផ បានមានប្រសាសន៍ថា នៅឆ្នាំ ២០០០ និង ២០០១ គ្រួសាររបស់លោកស្រី មិនអាចដាំស្រូវបានទាល់តែសោះ ដោយសារតែបរិមាណទឹកជំនន់ដែលពុំធ្លាប់មានពីមុនមក ដែលលោកស្រីបានមានប្រសាសន៍ថា មិនធ្លាប់មានអ្នកណាម្នាក់បានជួបប្រទះពីមុនឡើយ ។

នៅឆ្នាំ ២០០៣ អង្គការអុកស្វាម បានអនុវត្តនូវកម្មវិធីគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់សហគមន៍មួយ នៅភូមិចំនួន ១៣ ក្នុងចំណោមភូមិដាច់ស្រយាលនិងងាយរងគ្រោះបំផុត នៅខេត្តតាកែវ ក្នុងគោលបំណងដើម្បីកាត់បន្ថយនូវផលប៉ះពាល់គ្រោះធម្មជាតិលើសុវត្ថិភាពស្បៀង និងការរស់នៅរបស់ស្ត្រី និងបុរសនៅក្នុងតំបន់ទាំងនេះ ។

តាមរយៈអង្គការដៃគូរបស់ខ្លួន ឈ្មោះចំរើនជនជាតិខ្មែរ (CCK) អង្គការអុកស្វាមបានផ្តល់ការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពស្តីពីការការពារទឹកជំនន់ បញ្ហាអនាម័យ និងបញ្ហាយល់ដឹងទាក់ទងយែនឌ័រដល់គណៈកម្មាធិការភូមិ គ្រប់គ្រងគ្រោះមហន្តរាយ (VCDM) ដែលនឹងផ្ទេរបន្តនូវចំណេះដឹងនេះដល់សហគមន៍ ។

តាមរយៈដំណើរការជ្រើសរើសប្រកបដោយតម្លាភាពមួយ គណៈកម្មាធិការ VCDM នេះក៏បានផ្តល់នូវទូក មង និងបានជួយ ជួសជុលផ្ទះដល់គ្រួសារដែលត្រូវការជំនួយបំផុត ។

អង្គការអុកស្វាមបានជួយជួសជុលផ្ទះរបស់លោកស្រីបុប្ផក៏ដូចជាបានជួយក្រឹបផ្ទះរបស់លោកស្រីឡើង ដើម្បីឱ្យផុតពីទឹកជំនន់ ។ គ្រួសាររបស់លោកស្រី ក៏ត្រូវបានអង្គការផ្តល់ជូនទូក និង មងមួយចំនួយផងដែរ ។ លោកស្រីបានមានប្រសាសន៍ថា“ឥឡូវនេះខ្ញុំមិនចាំបាច់ព្រួយពីការជួសជុលផ្ទះតទៅទៀតទេ ។ ខ្ញុំមានពេលវេលាដើម្បីរកត្រី ជាពិសេសជាមួយទូកមួយខ្ញុំអាចរកត្រីបានច្រើន ដើម្បីទទួលទាន ក៏ដូចជាសំរាប់លក់ផងដែរ ។”

ឥឡូវនេះ ក្នុងកំឡុងពេលទឹកជំនន់ លោកស្រីបុប្ផក៏ចេញទូករបស់លោកស្រីជារៀងរាល់ថ្ងៃ ដើម្បីបេះត្រកួនយកទៅលក់នៅព្រំដែនវៀតណាម ។

លោកស្រីបានមានប្រសាសន៍ថា “កូនប្រុសរបស់នាងខ្ញុំកាប់ឈើ និងបេះត្រកួនខណៈពេលនោះនាងខ្ញុំអុំទូក ។ យើងខ្ញុំត្រូវតែ បញ្ចប់នៅមុនថ្ងៃត្រង់ដើម្បីយកទៅលក់នៅព្រំដែនវៀតណាមហើយត្រូវត្រឡប់មកវិញមុនខ្យល់ខ្លាំងមកដល់នាពេលល្ងាច ប៉ុន្តែវាពិបាកនឹងធ្វើណាស់ ។”

លោកស្រីបុប្ផអាចរកប្រាក់ចំណូលបានប្រហែល ២០.០០០ រៀល ឬ ប្រាំដុល្លារអាមេរិក ដោយសារការលក់នូវរុក្ខជាតិដែលដុះក្នុងទឹក ។ លោក អ៊ុន សុក្រិត មន្ត្រីកម្មវិធីសៀងរបស់អុកស្វាមបានមានប្រសាសន៍ថា “ទូកបានជួយសហគមន៍យ៉ាងច្រើន ។ ដោយការលក់ត្រីនិងដើមត្រកួនតែមួយមុខប្រជាជនដែលជាផ្នែកនៃកម្មវិធីនេះអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ដើម្បីបន្តជីវិតរស់នៅរបស់ពួកគេ ។”

## PILOT PROJECT : Takéo Province

### គំរោងសាកល្បង: ខេត្តតាកែវ

*ALTHOUGH IT MIGHT BE DIFFICULT FOR ANYONE TO DETER THE FLOODS OR ASK FOR RAIN IN THE PADDY FIELDS OF THE DROUGHT-PRONE AREAS, IT IS, HOWEVER, POSSIBLE TO REDUCE THE LOSSES THROUGH PREPAREDNESS.*

Under the 1999 Disaster Risk Reduction programme, Oxfam in 2003 initiated its first Community-Based Disaster Risk Reduction (CBDRR) Project in Takéo forming a systematic framework in coping with adversity.

ទោះបីជាវាមានការពិបាកសំរាប់មនុស្សរាល់គ្នាដើម្បីទប់ទល់ទឹកជំនន់ ឬសូមទឹកភ្លៀងសំរាប់ស្រែនៅតំបន់ដែលពោរពេញដោយគ្រោះរាំងស្ងួតយ៉ាងណាក៏ដោយក៏វាអាចនឹងកាត់បន្ថយនូវការ បាត់បង់នានាតាមរយៈការការពារ ។

ក្រោមកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយឆ្នាំ ១៩៩៩ នៅឆ្នាំ ២០០៣ អង្គការអុកស្វាមបានផ្តួចផ្តើមនូវគំរោងកាត់បន្ថយ គ្រោះមហន្តរាយថ្នាក់សហគមន៍ (CBDRR) ជាលើកដំបូងរបស់ខ្លួននៅខេត្តតាកែវដោយការបង្កើតនូវក្របខ័ណ្ឌ តាមលក្ខណៈប្រព័ន្ធមួយក្នុងការទប់ទល់ជាមួយហេតុការណ៍អាក្រក់នានា ។







## Takéo Province Borders...

Takéo is a province bordering Vietnam to the south and the Mekong, Bassac and Tonle Sap Rivers to the East. The province is located in the Mekong Delta – a shallow low-lying area – where most of the country's water ways combine.

The yearly flood is characterised by extended areas inundated by water from the Bassac River, the Mekong River and the numerous natural and artificial canals linking the two rivers that flow laterally to low lands. High water levels in the Bassac/Mekong systems cannot drain easily to the sea because of tidal effects. Every year there is substantial damage from these high water levels, damaging houses and infrastructure.

Moreover, since the completion of a Vietnamese dam down stream in the year 2000, the area has experienced more irregular flooding with water rising faster, staying longer and receding slower; a pattern consistent with the restriction of water movement by a dam.

## ព្រំប្រទល់ខេត្តតាកែវ

ខេត្តតាកែវជាខេត្តមួយជាប់ព្រំប្រទល់ប្រទេសវៀតណាមបែកខាងត្បូង ទន្លេមេគង្គ ទន្លេបាសាក់ និងទន្លេសាបបែកខាងកើត ។ ខេត្តនេះមានទីតាំងនៅដីសណ្តរទន្លេមេគង្គ តំបន់ទំនាបរាក់មួយ ជាទីកន្លែងដែលផ្លូវទឹកនានារបស់ប្រទេសជួបគ្នា ។

ទឹកជំនន់រាល់ឆ្នាំត្រូវបានពិពណ៌នាដោយតំបន់ដែលមានវិសាលភាពដែលជន់លិចដោយទឹកមកពីទន្លេបាសាក់ ទន្លេមេគង្គ និងព្រែក និង ប្រឡាយធំៗនានាដែលតភ្ជាប់ទៅទន្លេទាំងពីរនេះដែលហូរទៅផ្នែកដីទំនាប ។ កំរិតទឹកខ្ពស់នៅក្នុងប្រព័ន្ធទន្លេបាសាក់ ទន្លេមេគង្គ មិនអាចហូរចូលទៅសមុទ្របានដោយងាយទេដោយសារតែឥទ្ធិពលទឹកជោរឬនាច ។ រៀងរាល់ឆ្នាំតែងតែមានការខូចខាតយ៉ាងធ្ងន់ធ្ងរដោយសារតែកំរិតទឹកខ្ពស់ទាំងនេះដោយការបំផ្លាញផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធ ។

ជាងនេះទៅទៀត ចាប់តាំងពីមានការបញ្ចប់នូវកសាងនូវទំនប់ទឹកវៀតណាមហូរចុះមក នៅក្នុងឆ្នាំ ២០០០ តំបន់នេះកាន់តែមានការជន់លិចរិតតែខ្លាំងខុសធម្មតាជាមួយការកើនឡើងនៃទឹកកាន់តែលឿន យូរ និងស្រកចុះយឺតដែលជាទំរង់មួយស្របជាមួយការកំណត់នូវចលនាទឹកដោយទំនប់មួយ ។





## Working in the Most Affected Districts

When higher water levels last too long, there is not only damage to the houses, roads and irrigation canals but also to rice production, as paddies are left submerged and unavailable for planting.

The strain of having to pick themselves up and start over again and again makes it difficult for people to equip themselves with the basic essentials they need to keep their families afloat.

**Oxfam came to help the people "live with floods".** Oxfam implemented the project through local partner Chamroen Chiet Khmer, the National Committee for Disaster Management (NCDM) and the Provincial Committee for Disaster Management (PCDM) in the districts of Borey Chulasar, Kampong Krasaing, Prey Yithkar and Chey Chok. These four districts suffered from severe floods in the years 2000 – 2002 when many farmers found it difficult to cultivate rice at all, leaving them with no food or income.

In 2003, the Takéo Project took shape focusing on flood risk reduction activities in 13 of the most remote and vulnerable villages.

## ធ្វើការនៅស្រុកដែលមានផលប៉ះពាល់បំផុត

នៅពេលដែលកំរិតទឹកខ្ពស់អូសបន្លាយពេលយូរពេក មិនត្រឹមតែមានការខូចខាតផ្ទះសម្បែង ផ្លូវ ប្រឡាយធារាសាស្ត្រប៉ុណ្ណោះទេ តែថែមទាំងមានការខូចខាតដល់ផលិតកម្មស្រូវផងដែរ ខណៈពេលដែលវាលស្រែជន់លិចនិងមិនអាចដាំដុះបាន ។

ទោះយ៉ាងណាក៏ដោយ ការទទួលរងគ្រោះជាបន្តបន្ទាប់និងការព្យាយាមងើបឡើងវិញម្តងហើយម្តងទៀត ធ្វើឱ្យប្រជាជនមានការលំបាកក្នុងការទទួលបានមកវិញនូវអ្វីដែលជាតំរូវការដ៏ចាំបាច់ដែលពួកគេត្រូវការដើម្បីផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ។

**អង្គការអុកស្វាមមកជួយប្រជាជន "រស់នៅជាមួយទឹកជំនន់" ។** អង្គការអុកស្វាមបានប្រតិបត្តិការនូវគំរោងតាមរយៈដៃគូក្នុងស្រុក អង្គការចំរើនជាតិខ្មែរ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) និងគណៈកម្មាធិការខេត្តទទួលបន្ទុកការគ្រប់គ្រងគ្រោះមហន្តរាយ (PCDM) នៅស្រុកបុរីជលសារ កំពង់ក្រសាំង ព្រៃយិត្តការ និងស្រុក ជ័យជោគ ។ ស្រុកទាំង៤នេះរងគ្រោះដោយសារទឹកជំនន់ដ៏ធ្ងន់ធ្ងរនៅឆ្នាំ ២០០០-២០០២ ខណៈពេលដែលមានកសិករជាច្រើនជួបប្រទះការលំបាកមិនអាចដាំដុះស្រូវបានទាល់តែសោះ ដោយធ្វើឱ្យពួកគេមិនមានស្បៀងនិងប្រាក់ចំណូល។

នៅឆ្នាំ ២០០៣ គំរោងនៅខេត្តតាកែវបានផ្តោតអារម្មណ៍ខ្លាំងលើសកម្មភាពកាត់បន្ថយគ្រោះទឹកជំនន់ នៅភូមិចំនួន ១៣ ក្នុងចំណោមភូមិដាច់ស្រយាលនិងងាយរងគ្រោះបំផុត ។

Ses Vong Sambath – Programme Coordinator for Chamroen Chiet Khmer (CCK) – explains

## HOW COMMUNITY-BASED DISASTER MANAGEMENT WAS IMPLEMENTED IN TAKÉO

លោក សេស វង្សសម្បត្តិ ប្រធានសំរបសំរួលកម្មវិធីរបស់អង្គការ ចំរើនជាតិខ្មែរ (CCK ) ពន្យល់ពី មូលហេតុដែលគំរោងគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន ត្រូវបានអនុវត្តនៅខេត្តតាកែវ



"It was in the year 2000, during the flood crisis, that Oxfam started working in Takéo by providing emergency relief in the form of plastic sheets, buckets, kitchen kits, seeds and food to those affected," said Ses Vong Sambath, programme coordinator for CCK in Takéo. Those who survived the disaster were on the verge of collapse because many lived below the poverty line and had little capacity to recover.

"Almost every year since the great floods, every monsoon season the water rises to alarmingly high levels and any chance of a recovery were washed away with the floods," said Mr.Sambath.

In an effort to empower people to live and cope with disasters, Oxfam together with CCK implemented a programme based on the needs of the community.

Out of the 13 Villages, 416 families were chosen by the villagers themselves on the basis of their economic situation and needs, such as female-headed households where the husbands were unable to work or the women were widowed

> "WITH THE HELP OF OXFAM, WHEN THE FLOODS ARE BACK THE COMMUNITY MIGHT SLEEP EASIER KNOWING THAT THEY ARE BETTER PREPARED" SAID MR SAMBATH.
>
> លោកសម្បត្តិបាននិយាយថា "ដោយមានការជួយរបស់អង្គការអុកស្វាម សហគមន៍អាចដេកបានស្រួលជាងមុនដោយដឹងថាពួកគេបានរៀបចំល្អជាងមុននៅពេលទឹកជំនន់ឡើងមកម្តងទៀត" ។

លោក សេស វង្សសម្បត្តិ ប្រធានសំរបសំរួលកម្មវិធីរបស់ CCK ប្រចាំនៅខេត្តតាកែវបានមានប្រសាសន៍ថា "ក្នុងកំឡុងពេលមានវិបត្តិទឹកជំនន់នៅក្នុងឆ្នាំ ២០០០ អង្គការអុកស្វាមបានចាប់ផ្តើមការងារនៅខេត្តតាកែវដោយការផ្តល់នូវជំនួយសង្គ្រោះបន្ទាន់រួមមាន ថង់ប្លាស្ទិក ធុង ប្រដាប់ប្រដាផ្ទះបាយ ពូជ ស្បៀងដល់អ្នកដែលបានរងគ្រោះទាំងនោះ" ។ អ្នកដែលរស់នៅជួបប្រទះគ្រោះមហន្តរាយស្ទើរតែដួលរលំទៅហើយ ដោយសារតែប្រជាជនជាច្រើនរស់នៅក្រោមបន្ទាត់ក្រីក្រ និង មានសមត្ថភាពតិចតួចដើម្បីវិលមករកភាពដើមវិញ ។

លោក សម្បត្តិ បានមានប្រសាសន៍ថា "ស្ទើរតែរៀងរាល់ឆ្នាំ ចាប់តាំងពីមានគ្រោះទឹកជំនន់ធំៗមក រៀងរាល់រដូវខ្យល់មូសុង ទឹកតែងតែឡើងយ៉ាងខ្លាំងដល់កំរិតខ្ពស់ ហើររាល់ឱកាសណាមួយនៃការវិលមករកភាពដើមវិញត្រូវបានបោះសំអាតទៅជាមួយទឹកជំនន់" ។

នៅក្នុងកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យប្រជាជនអាចរស់នៅទប់ទល់បានជាមួយគ្រោះមហន្តរាយ អង្គការអុកស្វាមរួមជាមួយអង្គការCCK បានប្រតិបត្តិការនូវកម្មវិធីមួយដោយផ្អែកលើតំរូវការនានារបស់សហគមន៍ ។

ក្នុងចំណោមភូមិ ១៣នេះ គ្រួសារចំនួន ៤១៦ ត្រូវបានជ្រើសរើសដោយអ្នកភូមិខ្លួនឯង ដោយផ្អែកលើមូលដ្ឋាននៃស្ថានភាព និងតំរូវការសេដ្ឋកិច្ចរបស់ពួកគេ ដូចជាគ្រួសារដែលដឹកនាំដោយស្ត្រី ខណៈពេលប្តីមិនអាចធ្វើការបាន ឬ ស្ត្រីមេម៉ាយ ។

លោកសម្បត្តិ បានមានប្រសាសន៍ថា "ជាមួយជំនួយរបស់អង្គការ អុកស្វាមនៅពេលមានទឹកជំនន់ម្តងៗ សហគមន៍អាចគេងលក់ស្រួលជាងមុនដោយសារតែដឹងថាពួកគេមានការប្រុងប្រៀបរៀបចំបានល្អ" ។



## What the Community Wanted
## ជម្រើសអ្វីដែលសហគមន៍ចង់បាន

### Shelter:
### ទីជំរក

It has become expensive for families to build good quality elevated houses. Small homes of bamboo and thatch have become the norm. These small accommodations are very susceptible to damage by heavy rains, strong winds and flooding. Oxfam and CCK helped communities build safe houses with good quality wood.

Villagers learned to raise their homesteads by 2-3 meters using dirt to elevate the ground above flood level, which then provides a safe area for livestock underneath the houses. In an areas where there is no high ground, Oxfam and CCK created man-made hills, safe area, equipped with shelters and water supply for up to six villages together with cattle to relocate in case of emergencies.

វាត្រូវចំណាយលុយច្រើនសំរាប់គ្រួសារទាំងឡាយដើម្បីកសាងផ្ទះដែលល្អនិងមានគុណភាព ។ ផ្ទះតូចធ្វើពីឬស្សីនិងប្រកស្បូវក្លាយជារឿងធម្មតាទៅហើយ ។ លំនៅស្ថានដ៏តូចទាំងនេះងាយទទួលរងការខូចខាតណាស់ដោយសារទឹកភ្លៀងខ្លាំង ខ្យល់ខ្លាំង និងការជន់លិចខ្លាំង ។ អង្គការអុកស្វាម និង CCK បានជួយសហគមន៍កសាងផ្ទះសុវត្ថិភាពដោយធ្វើពីឈើមានគុណភាពល្អ ។

អ្នកភូមិបានសិក្សាដើម្បីលើកផ្ទះរបស់ពួកគេ ២-៣ ម៉ែត្រ ដោយការចាក់ដីឱ្យខ្ពស់ផុតពីកំរិតទឹកជំនន់ ខណៈនោះ ផ្តល់ជូននូវតំបន់សុវត្ថិភាពដល់សត្វនៅខាងក្រោមផ្ទះ ។ នៅតំបន់ដែលគ្មានទីទួលខ្ពស់ អង្គការអុកស្វាមនិង CCK បានរៀបចំឱ្យមានទីទួល តំបន់សុវត្ថិភាព សាងសង់ឱ្យមានទីជម្រកនិងការផ្គត់ផ្គង់ទឹកសំរាប់រហូតដល់ភូមិចំនួន ៦ ជាមួយសត្វគោក្របីដើម្បីបោះទីតាំងឡើងវិញនៅពេលដែលមានភាពអាសន្ន ។







## Means of Making a Living:
## មធ្យោបាយនៃការរស់នៅ

During the floods the only way of earning income is through fishing and collecting morning glory. However, armed with simple fishing rods and broken-down boats, it is difficult to earn substantial income for an individual let alone the family. Oxfam and CCK has helped provide families with boats, fishing nets, as well as vegetable seeds and pots so that families can grow vegetables when flood waters prevent ground-level planting.

ក្នុងកំឡុងទឹកជំនន់ មធ្យោបាយតែមួយគត់នៃការរកប្រាក់ចំណូលគឺតាមរយៈការនេសាទត្រីនិងបេះត្រកួន ។ ទោះយ៉ាងណាក៏ដោយ ដោយការបំពាក់ឧបករណ៍នេសាទសាមញ្ញៗ និងទូកបាក់បែក វាមានការលំបាកក្នុងការរកប្រាក់ចំណូលឱ្យបានច្រើនសំរាប់មនុស្សម្នាក់យកទៅចិញ្ចឹមគ្រួសារ ។ អង្គការអុកស្វាម និង CCK បានផ្តល់ជូនដល់គ្រួសារទាំងឡាយនូវទូកមង ក៏ដូចជាគ្រាប់ពូជបន្លែ និង ភាជន៍ដើម្បីឱ្យគ្រួសារទាំងនោះអាចដាំបន្លែបាននៅពេលដែលមានទឹកជំនន់មិនអាចដាំនៅលើដីបាន ។

## Training and Safety:
## ការបណ្តុះបណ្តាល និង សុវត្ថិភាព

Safety was made a top priority. Life jackets, water jars and water filters for safe drinking were distributed. The villagers also received training in:

- First aid and public health education
- The importance of saving firewood which could be used to heat water for purification
- Gender equality within the family.

សុវត្ថិភាពត្រូវបានកំណត់យកជាអាទិភាពខ្ពស់មួយ ។ អាវពោង ពាងទឹក និងប្រដាប់ជម្រោះទឹកសំរាប់ការហូបស្អាតត្រូវបានផ្តល់ជូនៈ

* ជំនួយបឋម និង ការអប់រំពីសុខភាពសាធារណៈ
* សារសំខាន់នៃការសន្សំអុស ដែលអាចប្រើប្រាស់ដើម្បីដាំទឹកសំរាប់ការសំលាប់មេរោគ
* សមភាពយេនឌ័រនៅក្នុងរង្វង់គ្រួសារ ។











"In order to inject money into the community, we helped them to develop sustainable livelihoods through Cash-for-Work schemes, such as house construction, boat building and raising homesteads."

“ដើម្បីដាក់លុយចូលទៅក្នុងសហគមន៍ យើងបានជួយពួកគេដើម្បីអភិវឌ្ឍន៍ទូវការរស់នៅប្រកបដោយនិរន្តរភាព តាមរយៈគំរោងនានាដែលប្រើលុយសំរាប់ការងារ ដូចជាការកសាងផ្ទះ ការធ្វើទូក និងការលើកផ្ទះ ។”

## Total Distribution 2003 - 2006
## ការបែងចែកសរុបសំរាប់ឆ្នាំ ២០០៣-២០០៦

| | |
|---|---|
| Houses Repaired<br>ផ្ទះត្រូវបានជួសជុល | 60 |
| Water Jars<br>ពាងទឹក | 81 |
| Water Filters<br>ធុងចំរោះទឹកស្អាត | 395 |
| Latrines<br>បង្គន់អនាម័យ | 10 |
| Boats Distributed<br>ទូកត្រូវបានផ្តល់ជូន | 195 |
| Fishing Nets<br>មងនេសាទ | 395 |
| Plant Pots<br>ផើងដំណាំ | 126 |
| Seed Kits<br>គ្រាប់ពូជដំណាំ | 150 |
| Trees<br>(Planted to prevent soil erosion)<br>កូនឈើ<br>(ដាំការពារការហូរច្រោះដី) | 75 |
| Bamboo<br>(Planted to serve as source for building material)<br>ឫស្សី (ដាំទុកធ្វើជាសំភារៈសាងសង់) | 75 |
| Homesteads Raised<br>ផ្ទះត្រូវបានសាងសង | 150 |

* Rain water containment ponds (both to provide earth for homestead raising and to serve as water source during the Dry months)
ស្រះដឹកលទឹកភ្លៀង
(ផ្តល់ទាំងដីសំរាប់សង់ផ្ទះ និងសំរាប់ធ្វើជាប្រភពទឹកប្រើប្រាស់នៅខែប្រាំង)

## THE COMMUNITY: A PILLAR OF STRENGTH

សហគមន៍ ៖ កំលាំងសសរទ្រូង



# The Community: A Pillar of Strength
## សហគមន៍: កំលាំងសសរទ្រូង

COMMUNITY-BASED DISASTER RISK REDUCITON (CBDRR) is a process in which at-risk communities are actively engaged in the identification, analysis, planning, monitoring and evaluation of disaster risks in order to reduce their vulnerabilities and enhance their capacities. People are at the heart of decision-making and implementation of disaster risk reduction activities.

Disaster Risk Reduction at the community level helps people form an understanding of the risks that may occur in their community by creating an environment to initiate discussions on their vulnerability.  It also acts to create awareness amongst people to take ownership and responsibility, to advocate and lobby government to support risk reduction activities and mobilise the community.

គំរោងកាត់បន្ថយគ្រោះមហន្តរាយថ្នាក់សហគមន៍ (CBDRR) គឺជាដំណើរការមួយដែលសហគមន៍ទាំងឡាយកំពុងប្រឈមនឹងគ្រោះថ្នាក់ត្រូវបានគេយកចិត្តទុកដាក់យ៉ាងសកម្មក្នុងការកំណត់រកការវិភាគ ការធ្វើផែនការ ការត្រួតពិនិត្យ និងវាយតំលៃទៅលើគ្រោះមហន្តរាយនានា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនសមត្ថភាពរបស់សហគមន៍ ។ ប្រជាជនគឺជាកំលាំងធាតុដ៏សំខាន់មិនអាចខ្វះបានក្នុងការធ្វើសេចក្តីសំរេចចិត្ត និងការអនុវត្តនូវរាល់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ ។

នៅកំរិតសហគមន៍ ជួយឱ្យប្រជាជនបង្កើតបាននូវការយល់ដឹងអំពីគ្រោះថ្នាក់នានាដែលអាចកើតមានឡើងនៅក្នុងសហគមន៍របស់ពួកគេ តាមរយៈការបង្កើតឱ្យមានបរិយាកាសមួយដើម្បីផ្តួចផ្តើមឱ្យមានការពិភាក្សានានាស្តីពីភាពងាយរងគ្រោះរបស់ពួកគេ ។ វាក៏មានតួនាទីបង្កើតឱ្យមានការយល់ដឹងក្នុងចំណោមប្រជាជនដើម្បីធ្វើជាម្ចាស់ការ និងការទទួលខុសត្រូវតស៊ូមតិ និងបញ្ចុះបញ្ចូលរដ្ឋភិបាល ដើម្បីសុំការគាំទ្រដល់សកម្មភាពកាត់បន្ថយគ្រោះមហន្តរាយ និងចងក្រងសហគមន៍ ។

# How We Work
## របៀបនៃការធ្វើការ

The Royal Government of Cambodia established a National Committee for Disaster Management (NCDM) in 1995 with the purpose of supporting:

1. Capacity building on disaster management for government officials at the Provincial, district, commune and village levels.
2. Emergency relief assistance, mobilisation of resources and provision of relief goods to affected people.
3. Community Based Disaster Risk Reduction programmes in collaboration with international and local non-governmental organisations.

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្នុងឆ្នាំ១៩៩៥ ដោយមានគោលបំណងគាំទ្រ:

១- ការកសាងសមត្ថភាពស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយដល់មន្ត្រីរាជរដ្ឋាភិបាលថ្នាក់ខេត្ត ស្រុក ឃុំ និងថ្នាក់ភូមិ

២- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ការប្រមូលនូវធនធានសំភារៈផ្សេងៗ និងការផ្តល់ជំនួយសង្គ្រោះផ្សេងៗ ដល់ប្រជាជនរងគ្រោះ

៣- កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយថ្នាក់សហគមន៍ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ ។




Oxfam's CBDRR projects are implemented through local partners and the various levels of the government's NCDM project. Each of Oxfam's provincial project team is made up of local NGO staff, officials from the National-CDM and Provincial-CDM and one Oxfam staff. The project team works to support the capacities and coping strategies of local communities. The villages themselves carry out most activities, including village mobilising, beneficiary selection, and the creation of a village action plan.

The Oxfam Great Britain head office in Phnom Penh provides technical support and training to both partners and local government.

គំរោង CBDRR របស់អង្គការអុកស្វាមត្រូវបានអនុវត្តតាមរយៈអង្គការដៃគូក្នុងស្រុកនានា និងតាមរយៈគំរោង NCDM គ្រប់លំដាប់របស់រាជរដ្ឋាភិបាល ។ ក្រុមការងារគំរោងថ្នាក់ខេត្តនីមួយៗរបស់អង្គការអុកស្វាមត្រូវបានបង្កើតឡើងដោយមានបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មន្ត្រីមកពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការខេត្តគ្រប់គ្រងគ្រោះមហន្តរាយ និងបុគ្គលិកម្នាក់របស់អង្គការអុកស្វាម ។ ក្រុមការងាររបស់គំរោងបំពេញការងារគាំទ្រលើសមត្ថភាព និងយុទ្ធសាស្ត្រដោះស្រាយសំរាប់សហគមន៍មូលដ្ឋាន។បណ្តាភូមិទាំងឡាយខ្លួនគេផ្ទាល់ ជាអ្នកអនុវត្តនូវសកម្មភាពភាគច្រើនបំផុត ដោយរួមបញ្ចូលទាំងការចងក្រងភូមិ ការជ្រើសរើសអ្នកទទួលផល និងការកសាងផែនការសកម្មភាពភូមិ ។

ការិយាល័យកណ្តាលរបស់អង្គការអុកស្វាមចក្រភពអង់គ្លេសនៅទីក្រុងភ្នំពេញ ផ្តល់នូវការគាំទ្រខាងបច្ចេកទេស និងការបណ្តុះបណ្តាលទៅដល់ទាំងអង្គការដៃគូ និងទាំងដល់រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ។

# How CBDRR is Implemented in Takéo
## តើ CBDRR ត្រូវបានអនុវត្តយ៉ាងដូចម្តេចនៅខេត្តតាកែវ

The CBDRR project in Takéo is implemented through a Village Committee for Disaster Management or VCDM. The members are made up of five women and men directly elected by their communities.

The government, Oxfam and local partners play a supportive role to the community through the provision of information, training and financial and technical assistance to VCDM members, in order for the committee to improve their community's resilience in the face of flood.

The VCDM organise to:

- Assist in the selection of beneficiaries by conducting vulnerability assessments
- Implement the construction of homesteads, rehabilitation of houses
- Distribute boats and water jars
- Implement village evacuation plans
- Guide vulnerable and often distraught villagers to safe areas, and distribute food and non-food items when needed
- Monitor and provide training on maintenance of distributed equipment.

គំរោង CBDRR នៅខេត្តតាកែវ ត្រូវបានអនុវត្តតាមរយៈគណៈកម្មាធិការភូមិគ្រប់គ្រងគ្រោះមហន្តរាយ រឺ VCDM ។ សមាជិកគណៈកម្មការត្រូវបានបង្កើតឡើងដោយមានស្ត្រីនិងបុរសចំនួន៥នាក់ ដែលជ្រើសរើសដោយសមាជិកសហគមន៍របស់ពួកគេដោយផ្ទាល់ ។

រដ្ឋាភិបាល, អង្គការអុកស្វាម និងដៃគូក្នុងស្រុកនានា ដើរតួនាទីជាអ្នកគាំទ្រសហគមន៍តាមរយៈការផ្តល់ពត៌មាន ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុទៅដល់សមាជិក VCDM ដើម្បីឱ្យគណៈកម្មការមានលទ្ធភាពកែលំអឱ្យមានភាពងើបរើឡើងវិញរបស់សហគមន៍ដែលប្រឈមនឹងគ្រោះទឹកជំនន់ ។

VCDM បង្កើតឡើងដើម្បី:

* ជួយជ្រើសរើសអ្នកទទួលផលតាមរយៈការធ្វើការវាយតំលៃអំពីភាពងាយរងគ្រោះ
* អនុវត្តការសាងសង់ផ្ទះ ការជួសជុលផ្ទះ
* ចែកទូក និង ពាងទឹក
* អនុវត្តផែនការជម្លៀសអ្នកភូមិ
* ដឹកនាំអ្នកភូមិដែលងាយរងគ្រោះ និងអ្នករងគ្រោះទៅកាន់ទីតាំងសុវត្ថិភាព និងចែកស្បៀងអាហារ និងសំភារៈមិនមែនជាស្បៀងអាហារនៅពេលគេត្រូវការចាំបាច់
* ត្រួតពិនិត្យនិងផ្តល់ការបណ្តុះបណ្តាលស្តីពីការថែរក្សាសំភារៈឧបករណ៍ដែលបានចែក







# Accountability to Beneficiaries, Stakeholders and Donors

# គណនេយ្យភាពចំពោះអ្នកទទួលផល, អ្នកពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយ

## Accountability Network

In order to improve the quality of humanitarian response, Oxfam helped found self-monitoring humanitarian accountability network of non-governmental organisations working in Cambodia.

HANet or the Humanitarian Accountability Network in Cambodia has more than 20 members including both local and international non-governmental organisations. Through this network, members have developed concrete strategies to improve accountability and transparency during disaster preparedness, mitigation and response. HANet members promote the use of complaint handling mechanisms at the onset of activities so that beneficiaries and stakeholders have the means to communicate their grievances. This allows project teams to identify and resolve problems rapidly and so improved programme quality.

## បណ្តាញការងារនៃការទទួលខុសត្រូវខ្ពស់

ដើម្បីលើកកំពស់គុណភាពនៃការឆ្លើយតបផ្នែកមនុស្សធម៌, អង្គការអុកស្វាម បានជួយបង្កើតឱ្យមានបណ្តាញគណនេយ្យភាព មនុស្សធម៌ស្វ័យត្រួតពិនិត្យ របស់អង្គការមិនមែនរដ្ឋាភិបាលនានាដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ។

HANet ឬ បណ្តាញគណនេយគណនេយ្យភាពមនុស្សធម៌នៅកម្ពុជា មានសមាជិកជាង ២០ អង្គការរួមមានទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ។ តាមរយៈបណ្តាញនេះ សមាជិកគ្រប់រូបបានអភិវឌ្ឍនូវយុទ្ធសាស្ត្រជាក់ច្បាស់ដើម្បីលើកកំពស់នូវគណនេយ្យភាព និងតម្លាភាពសំរាប់ការត្រៀមបង្ការ ការកាត់បន្ថយ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ ។ សមាជិករបស់ HANet លើកទឹកចិត្តឱ្យប្រើប្រាស់យន្តការដោះស្រាយទំនាស់នៅនឹងកន្លែងធ្វើសកម្មភាពការងារផ្ទាល់ដើម្បីឱ្យអ្នកទទួលផលនិងអ្នកពាក់ព័ន្ធទាំងអស់មានមធ្យោបាយធ្វើទំនាក់ទំនងអំពីសេចក្តីទុក្ខរបស់ពួកគេ ។ ការងារនេះអនុញ្ញាតិឱ្យក្រុមការងារគំរោងកំណត់រក និងដោះស្រាយបញ្ហាជាបន្ទាន់ ហើយការធ្វើដូចនេះធ្វើឱ្យប្រសើរឡើងនូវគុណភាពកម្មវិធី ។

## Takéo Programme Evaluated

In 2006 the Takéo pilot project was handed over to the local partner Chamroen Chiet Khmer (CCK). CCK has proven itself to be a professional local development agency and has taken full responsibility for the application and maintenance of the programme in Takeo province.

Before the handover, Oxfam, with the help of an external consultant, conducted a participatory three-week evaluation of the project. It was found that the project was widely considered as a model for community-based disaster risk reduction, and was, more importantly, seen by the community themselves as having had real impact to improve their resilience to flood.

## គំរោងកម្មវិធី នៅខេត្តតាកែវត្រូវបានវាយតំលៃ

នៅឆ្នាំ ២០០៦ គំរោងសាកល្បងនៅខេត្តតាកែវបានផ្តល់ទៅឱ្យអង្គការចំរើនជាតិខ្មែរ (CCK) ជាអង្គការដៃគូក្នុងស្រុក ។ អង្គការ CCK បានបង្ហាញឱ្យឃើញខ្លួនឯងថាជាភ្នាក់ងារអភិវឌ្ឍន៍អាជីពក្នុងស្រុកមួយ និងមានការទទួលខុសត្រូវពេញលេញលើការអនុវត្តន៍ និងការថែរក្សាកម្មវិធីនៅខេត្តតាកែវ ។

មុនការប្រគល់ជូនគំរោងនេះ អង្គការអុកស្វាមដោយមានការជួយរបស់ទីប្រឹក្សាខាងក្រៅអង្គការម្នាក់បានធ្វើការវាយតំលៃគំរោង តាមបែបលក្ខណៈចូលរួមមួយមានរយៈពេល ៣ សប្តាហ៍ ។ ការវាយតំលៃនេះបានរកឃើញថាគំរោងនេះ ត្រូវបានចាត់ទុកយ៉ាង ទូលំទូលាយថាជាគំរូមួយសំរាប់ការកាត់បន្ថយគ្រោះមហន្តរាយថ្នាក់សហគមន៍ ហើយសំខាន់ជាងនេះទៀត សហគមន៍ខ្លួនគេផ្ទាល់បានមើលឃើញថា បានទទួលផលវិជ្ជមានពិតប្រាកដដើម្បីកែលំអនូវភាពងើបរើឡើងវិញរបស់ពួកគេពីគ្រោះទឹកជំនន់ ។





The training provided by Oxfam in collaboration with CCK throughout the years had grown in depth and complexity benefiting not just the villagers but also government officials and members of the international NGO community.

- Targeting: The evaluation team was impressed with the targeting process (wealth ranking by VCDMs). The most vulnerable were identified and received the benefits.
- The VCDMs have the potential to be independent village institutions, acting in partnership with government village institutions (VDCs)
- By determining the gender composition of the VCDMs (three women and two men) the structure of the committee helps address women's practical needs and interests.
- VCDMs and the community have formed a bond which instills confidence in coping with adverse disasters.
- The programme has been acknowledged and valued by the Cambodian government.

ការបណ្តុះបណ្តាលដែលផ្តល់ដោយអង្គការអុកស្វាមសហការជាមួយអង្គការ CCK អស់ពេលជាច្រើនឆ្នាំមកនេះ បានរីកចំរើនយ៉ាងជ្រាលជ្រៅ និងផ្តល់ផលប្រយោជន៍គ្រប់យ៉ាង មិនត្រឹមតែសំរាប់អ្នកភូមិប៉ុណ្ណោះទេ ក៏ប៉ុន្តែសំរាប់មន្ត្រីរដ្ឋាភិបាល និងសមាជិកសហគមន៍អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិផងដែរ ។

* ការកំណត់ក្រុមគោលដៅ: ក្រុមវាយតំលៃផ្តោតអារម្មណ៍ខ្លាំងលើដំណើរការកំណត់ក្រុមគោលដៅ (ការធ្វើចំណាត់ ថ្នាក់ធនធានដោយក្រុម VCDMs) ។ អ្នកភូមិដែលងាយទទួលគ្រោះភាគច្រើនបំផុតត្រូវបានកំណត់រកឃើញ ហើយបានទទួលផលប្រយោជន៍ ។
* ក្រុម VCDMs មានសក្តានុពលធ្វើជាស្ថាប័នភូមិឯករាជ្យ ដើរតួជាដៃគូជាមួយស្ថាប័នរដ្ឋអំណាចភូមិ (VDCs)
* តាមការកំណត់ឱ្យមានសមាសភាពយែនឌ័រនៅក្នុង VCDMs (ស្ត្រី ៣ នាក់ និងបុរស២ នាក់) រចនាសម្ព័ន្ធរបស់គណៈកម្មាធិការនេះជួយបង្ហាញឱ្យឃើញពីចំណាប់អារម្មណ៍និងតំរូវការចាំបាច់របស់ស្ត្រី
* VCDMs និងសហគមន៍បានបង្កើតខ្សែបណ្តាញមួយដែលនឹងបង្កើតឱ្យមានជំនឿទំនុកចិត្តគ្នាក្នុងការដោះស្រាយគ្រោះមហន្តរាយទាំងឡាយ ។
* គំរោងកម្មវិធីនេះត្រូវបានទទួលស្គាល់និងវាយតំលៃដោយរដ្ឋាភិបាលកម្ពុជា





## Conclusion

The flood mitigation project has grown in sophistication in all aspects from communications, community-based training, establishing of VCDMs, targeting and working with vulnerable populations to incorporating government support and influencing multilateral institutions. It has now become a strong model that can become a benchmark for other future projects.

## សេចក្ដីសន្និដ្ឋាន

គំរោងកាត់បន្ថយគ្រោះថ្នាក់ដោយទឹកជំនន់ បានរីកចំរើនឡើងគ្រប់ទិដ្ឋភាពទាំងអស់ចាប់តាំងពីវិស័យទំនាក់ទំនង, ការបណ្ដុះបណ្ដាលថ្នាក់សហគមន៍, ការបង្កើត VCDMs, ការកំណត់ក្រុមគោលដៅ និងការធ្វើការជាមួយប្រជាជនដែលងាយរងគ្រោះដោយមានការចូលរួមគាំទ្រពីរដ្ឋាភិបាល និងស្ថាប័នដែលមានឥទ្ធិពលជាច្រើនទៀត ។ បច្ចុប្បន្នគំរោងនេះបានក្លាយជាគំរូដ៏ខ្លាំងមួយដែលអាចធ្វើជាលំនាំគំរូសំរាប់គំរោងផ្សេងៗទៀតនាពេលអនាគត ។





# Gender Equality and Disaster Preparedness
## សមភាពយេនឌ័រ និងការត្រៀមបង្ការគ្រោះមហន្តរាយ

### Women and Disasters

- Women are seldom represented on decision-making bodies before, during, and after disasters, and so their needs and interests are not taken into account.
- Women tend to be regarded as helpless victims who need to be protected and told what to do rather than potential resources.
- Little attention is paid to women's needs when it comes to emergency-relief, in terms of their need for privacy, personal hygiene, sanitation and health.
- The use of alcohol and drugs by men often increases at a disaster site, particularly when women lose control over income, and men become depressed about their inability to provide for their families. Alcohol and drug use deplete family resources and increase domestic violence.

To address these issues and work towards gender equity, the disaster risk reduction project and emergency response in Takéo was drawn up within the following guidelines

### ស្ត្រីនិងគ្រោះមហន្តរាយ

* ស្ត្រីកំរត្រូវបានគេឱ្យធ្វើជាតំណាងនៃក្រុមអ្នកធ្វើសេចក្តីសំរេចចិត្តណាស់ ទាំងមុនពេល ទាំងពេលកំពុងកើតមាន និង ក្រោយពេលកើតមានគ្រោះមហន្តរាយ ដូច្នេះហើយចំណាប់អារម្មណ៍និងសេចក្តីត្រូវការរបស់ពួកគេមិនដែលត្រូវបានគេយកចិត្តយកទុកដាក់គិតគូរឡើយ ។
* ស្ត្រីហាក់មានទំនោរដែលត្រូវបានគេចាត់ទុកថាជា ជនរងគ្រោះគ្មានទីពឹងដែលត្រូវការចាំបាច់ឱ្យគេការពារ និងគេប្រាប់នូវអ្វីដែលត្រូវធ្វើជាជាងប្រាប់នូវអ្វីដែលជាធនធានប្រកបដោយសក្តានុពល ។
* គេចាប់អារម្មណ៍តិចតួចទៅលើតំរូវការរបស់ស្ត្រីនៅពេលដែលត្រូវការជំនួយសង្គ្រោះបន្ទាន់ ក្នុងន័យតំរូវការចាំបាច់ជាលក្ខណៈឯកជនរបស់ពួកគេ អនាម័យផ្ទាល់ខ្លួន អនាម័យនិងសុខភាព ។
* ការប្រើប្រាស់គ្រឿងស្រវឹងនិងគ្រឿងញៀនដោយពួកបុរសៗ ជាញឹកញាប់មានការកើនឡើងនៅកន្លែងគ្រោះមហន្តរាយ, ជាពិសេសនៅពេលស្ត្រីបាត់បង់ស្មារតីម្ចាស់ការក្នុងការរកចំណូល ហើយពួកបុរសៗក៏ក្លាយទៅជាធ្លាក់ទឹកចិត្តចំពោះ អលទ្ធភាពរកប្រាក់ចំណូលផ្តល់ឱ្យគ្រួសាររបស់គេ ។ ការប្រើប្រាស់គ្រឿងស្រវឹងនិងគ្រឿងញៀនបានបំផ្លាញទ្រព្យសម្បត្តិគ្រួសារឱ្យហិនហោច និងបង្កឱ្យមានអំពើហិង្សាក្នុងគ្រួសារ ។

ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ហើយធ្វើការសំដៅលើកកំពស់សមភាពយេនឌ័រនោះ គំរោងកាត់បន្ថយគ្រោះមហន្តរាយ និងជំនួយសង្គ្រោះបន្ទាន់នៅខេត្តតាកែវត្រូវបានបង្កើតឡើងតាមគោលការណ៍ដូចខាងក្រោម ។





## Initial Assessment and Project Design

- Women in the community provide project team with information on cultural norms and practices
- Women in the community actively participate in needs assessment and project design.

## ការវាយតំលៃបឋម និង ការបង្កើតគំរោង

* ស្ត្រីក្នុងសហគមន៍ផ្តល់ឱ្យក្រុមការងារនូវព័ត៌មានស្តីពីបទដ្ឋានខាងវប្បធម៌ និងការអនុវត្ត ។
* ស្ត្រីក្នុងសហគមន៍ចូលរួមយ៉ាងសកម្មក្នុងការវាយតំលៃតំរូវការនិងការបង្កើតគំរោង

## Project Implementation and Monitoring

- VCDM membership include both women and men
- Meetings are held to discuss the issue of violence against women and ways of reducing sexual harassment within the community
- Women have a key role in the targeting, monitoring and distribution project resources
- Female beneficiaries have access and share control over project resources and benefits
- Public space is created to meet the different social needs of women and men, boys and girls is provided
- Activities such as house repair and cash-for-work are designed to ensure that female-headed households receive the same benefits as other families
- At least 80% of relief food aid is distributed directly to women
- Projects include food production and income-generating activities that enable women and girls to achieve minimum food and income security
- Women take a leading role in key project activities such as water-point management, income generating initiatives, and community mobilisation
- Women, men, and school children together provide health information to the rest of the community.

## ការអនុវត្ត និងត្រួតពិនិត្យគំរោង

* សមាជិកភាពរបស់ VCDM រាប់បញ្ចូលទាំងស្ត្រីនិងបុរស
* កិច្ចប្រជុំត្រូវបានធ្វើឡើងដើម្បីពិភាក្សាអំពីបញ្ហាអំពើហិង្សាប្រឆាំងនឹងស្ត្រីនិងស្វែងរកមធ្យោបាយកាត់បន្ថយការបៀតបៀនផ្លូវភេទនៅក្នុងសហគមន៍
* ស្ត្រីមានតួនាទីសំខាន់ក្នុងការកំណត់ក្រុមគោលដៅ ការត្រួតពិនិត្យនិងការចែកចាយធនធានរបស់គំរោង
* អ្នកទទួលផលជាស្ត្រីមានលទ្ធភាពនិងចូលរួមមើលខុសត្រូវលើធនធាននិងផលប្រយោជន៍របស់គំរោង
* បង្កើតឱ្យមានកន្លែងសាធារណៈដើម្បីជួបប្រជុំដោះស្រាយអំពីតំរូវការផ្សេងៗក្នុងសង្គមរបស់បុរសនិងស្ត្រី ក្មេងប្រុស និង ក្មេងស្រី
* សកម្មភាពទាំងឡាយដូចជាការជួសជុលផ្ទះនិងប្រាក់សំរាប់ការងារត្រូវបង្កើតឱ្យមានដើម្បីធានាថា ស្ត្រីជាមេផ្ទះក៏ទទួលបានអត្ថប្រយោជន៍ដូចគ្នានឹងគ្រួសារដទៃទៀតដែរ ។
* យ៉ាងតិចណាស់ក៏៨០% នៃជំនួយស្បៀងអាហារសង្គ្រោះត្រូវចែកផ្ទាល់ទៅស្ត្រី
* គំរោង រួមបញ្ចូលទាំងផលិតកម្មស្បៀងអាហារ និងសកម្មភាពបង្កើតប្រាក់ចំណូលដែលអាចឱ្យស្ត្រីនិងក្មេងស្រីសំរេចទទួលបាននូវសន្តិសុខស្បៀងនិងប្រាក់ចំណូលជាអប្បរិមា ។
* ស្ត្រីមានតួនាទីដឹកនាំក្នុងសកម្មភាពការងារសំខាន់ៗរបស់គំរោងការគ្រប់គ្រងស្រះទឹក និងការផ្តួចផ្តើមគំនិតបង្កើនប្រាក់ចំណូល និងការចងក្រងសហគមន៍ ។
* ស្ត្រី បុរសនិងសិស្សសាលារួមគ្នាផ្តល់ព័ត៌មានអំពីសុខភាពទៅដល់មនុស្សដទៃទៀតនៅក្នុងសហគមន៍ ។





## Gender Assessment

Three years since the Takéo project was first implemented, in 2006, an assessment was carried out to determine people's behaviour and attitude towards gender equity. It was found that:

- Women were better represented within the community's decision-making process
- Violence against women – domestic and sexual harassment – was reduced.

Female VCDM members say that they were more confident to speak out. Along the way they have gained knowledge and are able to take action, such as consulting with and helping fellow community members resolve conflicts. From this they have earned greater respect and recognition from community members.

Domestic violence has also reduced. With a more stable income from the success of the project, there is less tension within the family. Men have also learnt more about gender equality from the training process and are less inclined to use violence.

## ការវាយតំលៃយែនឌ័រ

អស់រយៈពេល ៣ ឆ្នាំហើយ ចាប់តាំងពីគំរោងកម្មវិធីនៅខេត្តតាកែវចាប់ផ្តើមអនុវត្តដំបូង, នៅឆ្នាំ ២០០៦ ការវាយតំលៃមួយបានធ្វើឡើងដើម្បីកំណត់ឱ្យឃើញអំពីឥរិយាបថនិងអាកប្បកិរិយារបស់ប្រជាជនទៅលើសមធម៌យែនឌ័រ ។ ការវាយតំលៃបានរកឃើញថា:

* ស្ត្រីធ្វើជាតំណាងបានយ៉ាងល្អនៅក្នុងដំណើរនៃការធ្វើសេចក្តីសំរេចចិត្តរបស់សហគមន៍
* អំពើហិង្សាប្រឆាំងនឹងស្ត្រី ដូចជាការបង្កបញ្ហាក្នុងគ្រួសារនិងការបៀតបៀនផ្លូវភេទត្រូវបានកាត់បន្ថយ

សមាជិក VCDM ជាស្ត្រីនិយាយថា ពួកគេមានទំនុកចិត្តកាន់តែច្រើនឡើងក្នុងបញ្ចេញមតិ ។ ជាមួយគ្នានេះដែរ ពួកគេក៏ទទួលបានចំណេះដឹងហើយអាចអនុវត្តសកម្មភាពបានដូចជាការប្រឹក្សាយោបល់ និងជួយដល់សមាជិករួមការងារសហគមន៍ក្នុងការដោះស្រាយទំនាស់ទៀតផង ។ តាមរយៈទង្វើទាំងនេះ ជាលទ្ធផលពួកគេទទួលនូវការគោរពខ្ពស់និងទទួលស្គាល់ពីសមាជិកសហគមន៍ថែមទៀត ។

អំពើហិង្សាក្នុងគ្រួសារក៏ត្រូវបានកាត់បន្ថយផងដែរ ។ ដោយទទួលបានចំណូលពីជោគជ័យរបស់គំរោងកាន់តែមានស្ថេរភាព ធ្វើឱ្យមានសំពាធគាបសង្កត់តិចតួចនៅគ្រួសារ ។ ពួកបុរសៗក៏បានយល់ដឹងច្រើនផងដែរអំពីសមភាពយែនឌ័រតាមរយៈដំណើរការបណ្តុះបណ្តាល ហើយគេក៏ពុំសូវប្រើប្រាស់អំពើហិង្សាទៀតដែរ ។





# Scaling Up

ការកើនឡើង



# Not Giving Up on Dry Land

## មិនបោះបង់ចោលទោះបីជាដីស្ងួតហួតហែងក៏ដោយ

Every day, villagers in rural Cambodia leave home in search of a better life in the city.  Success stories of comfortable jobs in factories and restaurants told by those who ventured ahead, is an opportunity far too tempting to pass up.

Many, living in drought prone areas, sell their dry land to the wealthy or land speculators and move to the capital, Phnom Penh.  Others have no choice but to enter the labour market after using up all their property to pay for medical care of family members.

However, for Nen Suwn, a 37-year-old mother of seven, her land, no matter how dry the paddy fields might get, is more than just a piece of asset.  It was handed down from her father and is something she wants to hold on to and pass it on to her children.  “I have lived here all my life. I see my neighbours sell their land and move out, but I love it here and I don’t want to give it up,” said Mrs Nen.

Mrs Nen lives in Kong Pisey district, Kompong Speu province, one of the country’s worst drought-hit areas in the past five years according to Cambodia’s National Committee for Disaster Management (NCDM).

Cambodia has been suffering from irregular dry spells throughout the past decade. Various parts of the country are going through prolonged drought during the planting season drying up the paddy fields and killing off the rice plants before they have fully grown.

Mrs Nen claims that in the past, when she could not grow enough rice to feed her family, she used to cut down trees but the hills are now empty and the only thing she can do now is sell labour, which earns her around 3,000 riel (less than 1 US dollar) per day.

Oxfam working with local partner– National Prosperity Association (NAPA) – has recently introduced a community-based disaster risk reduction project in 15 villages of Kong Pisey district.

“The project purpose is to utilise the various natural and man-made resources within the area to better equip the villagers living in increasing drier climate and in return help them to stay home and not have to move to the city,” said Som Vanthat Oxfam’s drought programme assistant.

ជារៀងរាល់ថ្ងៃ  អ្នកភូមិដែលរស់នៅតាមជនបទនៃប្រទេសកម្ពុជា បានចាកចេញពីផ្ទះសំបែងទៅស្វែងរកការងារចិញ្ចឹមជីវិតនៅទីក្រុង  ។  រឿងរ៉ាវជោគជ័យនៃការងារល្អប្រសើរនៅតាមរោងចក្រ និងភោជនីយដ្ឋាន អ្នកដែលធ្លាប់ចេញស្វែងរកការងារមុនៗ បាននិយាយថា គឺជាឱកាសដែលត្រូវតែចាប់យក មិនត្រូវឱ្យកន្លងផុតឡើយ  ។

អ្នកភូមិជាច្រើនដែលរស់នៅតាមតំបន់ដែលតែងតែជួបគ្រោះរាំងស្ងួតនោះ បានលក់ដីធ្លីរបស់ពួកគេទៅឱ្យពួកអ្នកមានឬឈ្មួញរកស៊ីដី  ហើយធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ  ។  អ្នកខ្លះទៀតគ្មានជំរើសអ្វីក្រៅតែពីទៅរកស៊ីឈ្នួលធ្វើការងារឱ្យគេបន្ទាប់ពីលក់អស់ទ្រព្យរបស់សំរាប់ព្យាបាលជំងឺសមាជិកគ្រួសារ  ។

ទោះជាយ៉ាងនេះក្តី លោកស្រីនេន សួន អាយុ៣៧ ឆ្នាំ មានកូន ៧ នាក់ បាននិយាយថា  ដីរបស់គាត់ទោះជាដីស្រែនោះជួបគ្រោះរាំងស្ងួតយ៉ាងណាក៏ដោយ ក៏វាសំខាន់ជាងទ្រព្យអ្វីៗទាំងអស់ ។ ឪពុករបស់គាត់បានចែកឱ្យគាត់ ហើយវាជាកេរ្តិ៍មរតកដែលគាត់ចង់ថែរក្សានិងចែកបន្តទៅកូនៗរបស់គាត់ ។  លោកស្រីនេននិយាយថា  “ខ្ញុំរស់នៅទីនេះអស់មួយជីវិត។  ខ្ញុំឃើញអ្នកភូមិរបស់ខ្ញុំលក់ដីធ្លីរបស់គេហើយចាកចោលភូមិស្រុក ប៉ុន្តែខ្ញុំស្រលាញ់ទីនេះហើយខ្ញុំមិនចង់បោះបង់ចោលទីនេះទេ”។

លោកស្រីនេនរស់នៅក្នុងស្រុកគងពិសី  ខេត្តកំពង់ស្ពឺ  ដែលជាតំបន់មួយក្នុងចំណោមតំបន់ផ្សេងៗជាច្រើនទៀតដែលទទួលរងគ្រោះរាំងស្ងួតធ្ងន់ធ្ងរបំផុតរបស់ប្រទេសកម្ពុជាកាលពី ៥ ឆ្នាំមុន យោងតាមព័ត៌មានរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា (NCDM)។

ប្រទេសកម្ពុជាបានទទួលរងគ្រោះដោយសារតែភាពរាំងស្ងួតមិនប្រក្រតីពេញមួយទសវត្សកន្លងទៅ ។ តំបន់ផ្សេងៗជាច្រើននៅទូទាំងប្រទេសត្រូវជួបនូវគ្រោះរាំងស្ងួតអូសបន្លាយយ៉ាងយូរនៅពេលរដូវដាំដុះដាំណាំធ្វើឱ្យដីស្រែចំការស្ងួតក្រៀមក្រោះ  និងបំផ្លាញអស់ដំណាំស្រូវនៅក្រោយពេលដាំដុះរួច  ។

លោកស្រីនេនបញ្ជាក់ថា  កាលពីមុននៅពេលដែលធ្វើស្រែមិនសូវបានផលសំរាប់ចិញ្ចឹមគ្រួសារ  គាត់ធ្លាប់ទៅកាប់ឈើលក់ប៉ុន្តែឥឡូវនេះ  នៅតាមភ្នំអស់ឈើរលីង  ហើយសព្វថ្ងៃនេះមានតែស៊ីឈ្នួលគេប៉ុណ្ណោះ  ដែលរកបានប្រហែល ៣០០០រៀល (តិចជាង ១ ដុល្លារ) ក្នុងមួយថ្ងៃ  ។

អង្គការអុកស្វាមសហការជាមួយអង្គការដៃគូក្នុងស្រុក,  អង្គការចំរើនជាតិ (NAPA) ដែលថ្មីៗនេះទើបនឹងបង្កើតឱ្យមានគំរោង កាត់បន្ថយគ្រោះមហន្តរាយដោយមានការចូលរួមពីសហគមន៍នៅក្នុងភូមិចំនួន១៥របស់ស្រុកគងពិសី  ។

Drought programme officer, Tep Sokha, explained that the rugged mountainous terrain of Kong Pisey receives considerable rain. During the Khmer Rouge regime, many reservoirs and dikes were built to harness the water but they have all fallen into disuse.

"We are now renovating the reservoirs and canals so that water can be irrigated to the paddy fields when there is drought so that the villagers don't have to rely solely on rain water to grow rice," he said.

Oxfam and NAPA plan to renovate five reservoirs and construct at least three canals by 2008. They have already completed several family and community ponds for rainwater catchments and underground wells to be used for drinking, feeding cattle and growing vegetables.

A Village Disaster Management Committees were established and was included in all the decision making process. The committees play a key role in educating their own communities on how to maintain the equipment, as well as other issues such hygiene and gender mainstreaming.

Sun Seng, 45, who had just received a family pond, said that she lives for from the water source, therefore, can only rely on the rain to keep her rice paddy from drying out.

"I look forward to when the canals are finished and maybe moving from my home land might not be a necessity," she said.

សំ វ៉ាន់ថាត ជំនួយការកម្មវិធីគ្រោះរាំងស្ងួតរបស់អង្គការអុកស្វាមមានប្រសាសន៍ថា "គោលបំណងរបស់គំរោងគឺដើម្បីប្រើប្រាស់នូវធនធានធម្មជាតិនិងធនធានសង្គមដែលមាននៅក្នុងតំបន់ដើម្បីជួយផ្គត់ផ្គង់ឱ្យប្រសើរឡើងដល់អ្នកភូមិដែលកំពុងរស់នៅជួបនឹងការកើនឡើងនៃកំដៅអាកាសធាតុ ហើយជាលទ្ធផលជួយឱ្យពួកគេស្ថិតនៅនឹងផ្ទះ និងមិនចាំបាច់ទៅរកការធ្វើនៅទីក្រុងទេ"។

លោកទេព សុខា ប្រធានកម្មវិធីគ្រោះរាំងស្ងួតបានពន្យល់ថា លក្ខណៈភូមិសាស្ត្រខ្ពង់រាបតំបន់ភ្នំរបស់ស្រុកគងពិសីមានភ្លៀងធ្លាក់គួរឱ្យគិតពិចារណា ។ នៅក្នុងរបបខ្មែរក្រហម ទំនប់ទឹកនិងប្រឡាយទឹកជាច្រើនបានសាងសង់ឡើងដើម្បីទាញយកទឹកសំរាប់ប្រើប្រាស់ ប៉ុន្តែទំនប់និងអាងទឹកទាំងនោះក៏បាក់រលាយខូចអស់មិនអាចប្រើប្រាស់ទៀតបាន ។

លោកបានមានប្រសាសន៍ថា "បច្ចុប្បន្ននេះយើងកំពុងជួសជុលស្តារទំនប់ទឹកនិងប្រឡាយទឹកទាំងនោះឡើងវិញដើម្បីឱ្យគេអាចយកទឹកបញ្ចូលទៅដាក់ក្នុងស្រែស្រូវបាននៅពេលដែលមានគ្រោះរាំងស្ងួត ដូច្នេះអ្នកភូមិនឹងមិនចាំបាច់ពឹងផ្អែកតែលើទឹកភ្លៀងសំរាប់ធ្វើស្រែទៀតឡើយ" ។

អង្គការអុកស្វាម និងអង្គការ NAPA មានផែនការស្តារឡើងវិញនូវទំនប់ទឹកចំនួន ៥ និងជីកប្រឡាយយ៉ាងតិចចំនួន៣ ខ្សែនៅឆ្នាំ ២០០៨ ។ ពួកគេបានជីកស្រះទឹកសហគមន៍ និងស្រះជាលក្ខណៈគ្រួសារជាច្រើនសំរាប់ស្តុកទឹកភ្លៀងរួចរាល់ហើយ ព្រមទាំងបានជីកអណ្តូកទឹកសំរាប់បរិភោគ ចិញ្ចឹមសត្វពាហណៈ និងស្រោចស្រពបន្លែ ។

គណៈកម្មាធិការភូមិគ្រប់គ្រងគ្រោះមហន្តរាយក៏បានបង្កើតឡើង ហើយបានដាក់ឱ្យទទួលបន្ទុកលើដំណើរការធ្វើសេចក្តីសំរេចចិត្តទាំងមូល ។ គណៈកម្មាធិការមានតួនាទីសំខាន់ក្នុងការអប់រំសហគមន៍របស់គេផ្ទាល់អំពីរបៀបថែទាំសំភារៈបរិក្ខា ព្រមទាំងបញ្ហាផ្សេងៗទៀតដូចជាអនាម័យនិងការបញ្ជ្រាបចំណេះដឹងយែនឌ័រជាដើម ។

លោកស្រីស៊ុន សេង អាយុ៤៥ ឆ្នាំ ដែលទើបបានទទួលស្រះទឹកជាលក្ខណៈគ្រួសារមួយនិយាយថា គាត់រស់នៅបានដោយសារតែមានប្រភពទឹកអីចឹងហើយមានតែពឹងលើទឹកភ្លៀងតែប៉ុណ្ណោះដើម្បីជួយស្រូវកុំឱ្យងាប់ ។

គាត់និយាយថា "ខ្ញុំរងចាំមើលនៅពេលណាគេជីកប្រឡាយហើយប្រហែលជាខ្ញុំមិនចាំបាច់ត្រូវចាកចោលស្រុកទេសរបស់ខ្ញុំឡើយ"។



# Scaling Up

Between 75 – 80 per cent of Cambodia's population live in rural areas with few monetary or physical resources with which to sustain their subsistence lives of poverty, or to build a base from which to escape out from under poverty's weight. Any shock, such as a natural disaster, can have a devastating impact on an already impoverished and vulnerable population.

The only effective course of action is to undertake efforts to prepare for and to minimise the impact of natural disaster and to provide communities with opportunities to shorten the time of recovery from flood or drought.

The Oxfam pilot project in Takéo has shown that the team has fashioned a methodology for community-based disaster risk reduction that has proven to be successful in improving people's resilience to natural disaster are less likely to be subjected to increased vulnerabilities.

Other NGOs have adopted or modified the approach in their own projects. Oxfam continues to share information with other Disaster Risk Reduction stakeholders, but sharing knowledge is not enough, there is more to be done to help other communities that have yet to receive assistance from other agencies.

Therefore, Oxfam's Disaster Risk Reduction programme has been extended to Kratie province and to drought affected communities in two provinces – Kampong Speu and Svay Rieng.

# ការកើនឡើង

នៅចន្លោះពី ៧៥-៨០ ភាគរយ នៃប្រជាជនកម្ពុជារស់នៅតាមទីជនបទ មានធនធានលុយកាក់ឬធនធានសំភារៈតិចតួច ដែលគ្រាន់ នឹងចិញ្ចឹមជីវិតរបស់គេរស់នៅក្នុងភាពក្រីក្រឬក៏បានជាមូលដ្ឋានដែលអាចរំដោះចេញពីទំងន់នៃភាពក្រីក្រ ។ សេចក្ដីភ័យតក់ស្លុតដូចជាគ្រោះធម្មជាតិអាចបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាជនដែលងាយរងគ្រោះនិងអ្នកដែលមានភាពក្រីក្រស្រាប់ ។

មធ្យោបាយសកម្មភាពដ៏មានប្រសិទ្ធិភាពគឺការខិតខំប្រឹងប្រែងត្រៀមបង្ការនិងធ្វើឱ្យថយចុះនូវផលប៉ះពាល់ពីគ្រោះធម្មជាតិហើយ ផ្ដល់ឱកាសឱ្យសហគមន៍ប្រើប្រាស់ពេលវេលាឱ្យបានខ្លីដើម្បីរួចរំដោះចេញពីទឹកជំនន់ឬក៏គ្រោះរាំងស្ងួត ។

គំរោងសាកល្បងរបស់អង្គការអុកស្វាមនៅខេត្តតាកែវបានបង្ហាញឱ្យឃើញថា ក្រុមការងារបានប្រើប្រាស់យ៉ាងល្អប្រសើរនូវវិធីសាស្ត្រសំរាប់កម្មវិធីកាត់បន្ថយគ្រោះមហន្តរាយដោយមានការចូលរួមពីសហគមន៍ដែលនាំឱ្យសំរេចជោគជ័យក្នុងការលើកកំពស់ឱ្យមានភាពងើបរើឡើងវិញរបស់ប្រជាជនទៅនឹងគ្រោះធម្មជាតិ ។

អង្គការផ្សេងៗទៀតបានយកទៅប្រើប្រាស់ឬក៏កែប្រែវិធីសាស្ត្រសំរាប់គំរោងផ្ទាល់របស់គេ ។ អង្គការអុកស្វាមបន្តចែករំលែកព័ត៌មានជាមួយអ្នកពាក់ព័នការងារកាត់បន្ថយគ្រោះមហន្តរាយ ប៉ុន្តែការចែករំលែកចំណេះដឹងគឺមិនបានគ្រប់គ្រាន់ឡើយ មានការងារជាច្រើនទៀតដែលត្រូវធ្វើដើម្បីជួយសហគមន៍ដទៃទៀតដែលមិនទាន់មានអ្នកជួយ ។

ហេតុដូច្នេះហើយបានជាកម្មវិធីកាត់បន្ថយគ្រោះមហន្តរាយរបស់អង្គការអុកស្វាមត្រូវពង្រីកគោលដៅទៅកាន់ខេត្តក្រចេះ និងសហគមន៍ដែលទទួលរងនូវគ្រោះរាំងស្ងួតនៅក្នុងខេត្តចំនួនពីរទៀតគឺ កំពង់ស្ពឺ និងស្វាយរៀង ។

## Drought in 2004, source from NCDM

| Provinces | Number of affected district | Agricultural land affected by drought |
|---|---|---|
| 1. Kampong Speu | 6 out of 8 | 90% |
| 2. Takeo | 4 out of 10 | 35% |
| 3. Prey Veng | 6 out of 12 | 45% |
| 4. Kandal | 3 out of 11 | 35% |




## Approach and Rationale

Oxfam applies the Community-Based Disaster Risk Reduction Framework in all three new privinces, working with local partner NGOs, NCDM and PCDM to establish independent village institutions, the VCDMs. Over the course of the new programme cycle, communities in 44 villages in the three provinces will be supported, including 19 villages affected by flood and 25 by drought.

## ការគាំទ្រ និង ហេតុផល

អង្គការអុកស្វាមអនុវត្តនូវក្របខ័ណ្ឌការងារកាត់បន្ថយគ្រោះមហន្តរាយថ្នាក់សហគមន៍ក្នុងខេត្តថ្មីទាំង៣ដោយ សហការជាមួយអង្គការដៃគូក្នុងស្រុកនានា, NCDM និង PCDM ដើម្បីបង្កើតស្ថាប័នភូមិឯករាជ្យ, VCDMs. អំពីរយះវេលានៃវដ្តរបស់គំរោងកម្មវិធីថ្មី សហគមន៍នៅក្នុងភូមិចំនួន៤៤ក្នុងខេត្តទាំង៣នឹងត្រូវបានឧត្ថម្ភគាំទ្រដោយរួមមានភូមិចំនួន១៩ដែលរងគ្រោះដោយទឹកជំនន់ និង ភូមិចំនួន២៥ ទទួលរងនូវគ្រោះរាំងស្ងួត ។

* Source : NCDM, August 2002




# Drought Programme
# កម្មវិធីគ្រោះរាំងស្ងួត

## Kompong Speu

A report released after the widespread drought of 2004 by Cambodia's National Committee for Disaster Management (NCDM) revealed that from 2002 – 2004 Kompong Speu Province suffered the most adverse effects of the irregular dry spells that have shaped the country during the last 10 years. Agricultural produce in six out of the eight districts were destroyed within the two-year time frame.

In recognition of the NCDM study, Oxfam conducted an assessment in 2005 and singled-out 15 villages in Korn Pisey district to be the worst hit.

## Implementing the Drought Preparedness Project

Oxfam began implementing the **Community-Based Drought Disaster Risk Reduction Project (CBDRRP)** in October 2006 in collaboration with local partner National Prosperity Association (NAPA). The characteristics is based on the community flood preparedness project in Takéo province but adapted to suit a drought prone area.

## កំពង់ស្ពឺ

របាយការណ៍មួយដែលបានចេញផ្សាយបន្ទាប់ពីគ្រោះរាំងស្ងួតគ្រប់ទីកន្លែងនៅឆ្នាំ២០០៤ដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយរបស់ប្រទេសកម្ពុជា (NCDM) បង្ហាញថា ពីឆ្នាំ ២០០២-២០០៤ ខេត្តកំពង់ស្ពឺបានទទួលរងគ្រោះញាំញីធ្ងន់ធ្ងរបំផុតពីភាពរាំងស្ងួតមិនប្រក្រតីដែលកើតមានឡើងនៅក្នុងប្រទេសកាលពីអំឡុងពេល១០ឆ្នាំមុន ។ ផលិតផលកសិកម្មនៅស្រុកចំនួន៦ ក្នុងចំណោមស្រុកទាំង៨ ត្រូវបានបំផ្លិចបំផ្លាញអស់ក្នុងរយៈពេល២ឆ្នាំ ។

ការទទួលស្គាល់តាមការសិក្សារបស់ NCDM, អង្គការអុកស្វាមបានធ្វើការវាយតំលៃមួយនៅក្នុងឆ្នាំ ២០០៥ ហើយបានរកឃើញថាភូមិចំនួន១៥ ក្នុងស្រុកគងពិសីត្រូវទទួលរងការវាយប្រហារធន់ធរបំផុត ។

## ការអនុវត្តគំរោងត្រៀមបង្ការសំរាប់គ្រោះរាំងស្ងួត

អង្គការអុកស្វាមចាប់ផ្តើមអនុវត្តគំរោងកាត់បន្ថយគ្រោះមហន្តរាយរាំងស្ងួតថ្នាក់សហគមន៍ (CBDRRP) នៅខែតុលា ឆ្នាំ ២០០៦ ក្នុងកិច្ចសហប្រតិបត្តិការជាមួយសមាគមចំរើនជាតិ (NAPA) ជាអង្គការដៃគូក្នុងស្រុក ។ លក្ខណៈការងារគឺយកលំនាំតាមគំរោងត្រៀមបង្ការទឹកជំនន់សហគមន៍នៅខេត្តតាកែវ ប៉ុន្តែអនុវត្តឱ្យស៊ីគ្នាទៅតាមតំបន់ដែលរងគ្រោះរាំងស្ងួត ។

## Problem

- *Relying Solely on Rain*

The community traditionally depends solely on rain to keep their rice plants alive. In a productive season, a one hectare rice paddy can produce roughly 1,000 kilogrammes of rice which can last a family the whole year. During the past 10 years, however, farmers have only been able to produce 500 kilogrammes and some, living far from water ways, are able to harvest just 50 kilogrammes. Households have to find alternative income by selling labour, cutting trees or moving to the city to find jobs.

- *No Safe Drinking Water*

Many water sources, including ponds and wells, dry up during the drought. The few remaining, used for personal hygiene, washing clothes, livestock, watering and drinking, become overused and contaminated, giving rise to water-borne diseases.

## Potential

- Eight out of the 15 villages are located close to mountainous areas and have access to water from streams that cascades down during the monsoon season. However, there is no available irrigation system and the water is not properly utilised.
- Within the area, there are also old reservoirs from the Khmer Rouge regime, if rehabilitated, can be use to effectively store water.
- Oxfam has also been working in the area since 2000 providing emergency drought response.

## បញ្ហា

* ពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង

ជាប្រពៃណីទៅហើយ សហគមន៍ពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀងដើម្បីស្រោចស្រពដំណាំស្រូវរបស់គេឱ្យរស់បាន ។ នៅក្នុងរដូវបង្កបង្កើនផលដីស្រែមួយហិកតាអាចផលិតស្រូវបានយ៉ាងច្រើនណាស ១០០០ គីឡូក្រាមដែលអាចចិញ្ចឹមគ្រួសារបានពេញមួយឆ្នាំ ។ ទោះយ៉ាងនេះក្ដីកាលពីអំឡុងពេល១០ឆ្នាំកន្លងទៅ កសិករអាចផលិតបានតែ ៥០០ គីឡូក្រាមប៉ុណ្ណោះ ហើយអ្នកខ្លះទៀត ដែលមានស្រែនៅឆ្ងាយពីផ្លូវទឹក អាចបានផលតែត្រឹម៥០ គីឡូក្រាមតែប៉ុណ្ណោះ។ គ្រួសារទាំងនោះត្រូវស្វែងរកចំណូលផ្សេងមកជំនួសដោយការស៊ីឈ្នួលគេ ការកាប់ឈើលក់ ឬក៏ទៅរកការងារធ្វើនៅទីក្រុង ។

* គ្មានទឹកស្អាតសំរាប់បរិភោគ

ប្រភពទឹកជាច្រើនរួមមានទាំងស្រះនិងអណ្ដូងក៏ត្រូវរីងស្ងួតអស់នៅពេលមានគ្រោះរាំងស្ងួត ។ ស្រះ ត្រពាំងតិចតួចដែលនៅសល់ដែលប្រើសំរាប់ឱ្យមានអនាម័យខ្លួនប្រាណ សំរាប់បោកគក់ ចិញ្ចឹមសត្វ ស្រោចស្រពដំណាំ និងសំរាប់បរិភោគក៏ត្រូវបានប្រើប្រាស់ហួសប្រមាណនិងធ្វើកខ្វក់ដែលបណ្ដាលឱ្យកើតជាជំងឺសើស្បែកផ្សេងៗ ។

## សក្ដានុពល

* ភូមិ ៨ ក្នុងចំណោមភូមិចំនួន១៥ មានទីតាំងនៅជិតនឹងតំបន់ភ្នំ ហើយមានលទ្ធភាពទទួលបានទឹកពីស្ទឹងដែលហូរចុះក្នុងរដូវវស្សា ។ ទោះជាយ៉ាងនេះក៏ពុំមានប្រព័ន្ធធារាសាស្ត្រសំរាប់តំកល់ទឹក ហើយទឹកត្រូវគេប្រើប្រាស់មិនបានសមស្របផងដែរ ។

* នៅក្នុងតំបន់ក៏មានទំនប់អាងទឹកចាស់ៗដែលសល់ពីរបបខ្មែរក្រហម ហើយប្រសិនបើគេជួសជុលឡើងវិញ វាអាចប្រើសំរាប់តំកល់ទឹកបានប្រកបដោយប្រសិទ្ធិភាព ។

* អង្គការអុកស្វាមក៏បាននិងកំពុងធ្វើការនៅក្នុងតំបន់នេះតាំងពីឆ្នាំ ២,០០០ ដោយបានផ្ដល់ជំនួយសង្គ្រោះបន្ទាន់ផ្នែកគ្រោះរាំងស្ងួត ។





## Providing what is needed

Water from one small reservoir can be irrigated to 50 – 100 hectares of rice paddy. Oxfam together with NAPA will construct as well as rehabilitate canals, culverts and reservoirs to irrigate water to the farmlands to replace rainfall in periods of drought. Oxfam also will construct wells, community and family ponds to collect rainfall for irrigating alternative crops, raising fish and for feeding livestock. VCDM members are currently learning about disaster management, accountability, hygiene, gender equality and community mobilising so that they can pass the information on to the community.




## Svay Rieng

In Svay Rieng, unlike Kampong Speu, Communities have sufficient drinking water but very poor irrigation system. Oxfam and local partner - PADEK - started disaster risk reduction activities in 10 villages in Svay Rieng province in January 2007.

## ផ្តល់នូវអ្វីដែលជាតំរូវការចាំបាច់

គេអាចយកទឹកពីទំនប់ទឹកតូចមួយទៅស្រោចស្រពលើដីស្រែពី ៥០-១០០ ហិកតា ។ អង្គការអុកស្វាមនិងអង្គការ NAPA នឹងជីក ព្រមទាំងជួសជុលប្រឡាយទឹក ប្រព័ន្ធបង្ហូរទឹក និងទំនប់ទឹក ដើម្បីយកទឹកទៅស្រោចស្រពដីស្រែជំនួសទឹកភ្លៀង នៅអំឡុងរាំងស្ងួត។ អង្គការអុកស្វាមក៏នឹងជីកអណ្តូង ជីស្រះទឹកសហគមន៍ និងស្រះទឹកជាលក្ខណៈគ្រួសារដើម្បីប្រមូលយកទឹកភ្លៀងសំរាប់ស្រោចស្រពដំណាំជំនួសផ្សេងៗ ចិញ្ចឹមត្រី និងសំរាប់សត្វចិញ្ចឹមផ្សេងទៀត ។ សមាជិក VCDM បច្ចុប្បន្ននេះកំពុងសិក្សាអំពីរបៀបគ្រប់គ្រងគ្រោះមហន្តរាយ អនាម័យ សមភាពយែនឌ័រ និងការចងក្រងសហគមន៍ ដើម្បីឱ្យពួកគេអាចចែកចាយព័ត៌មានបន្តទៅសហគមន៍ ។

## ស្វាយរៀង

នៅខេត្តស្វាយរៀងខុសពីខេត្តកំពង់ស្ពឺ សហគមន៍ទាំងឡាយមានទឹកផឹកគ្រប់គ្រាន់ ប៉ុន្តែពុំសូវមានប្រព័ន្ធធារាសាស្ត្រ។ អង្គការ អុកស្វាមនិងអង្គការ PADEK ដែលជាដៃគូការងារក្នុងស្រុក បានចាប់ផ្តើមអនុវត្តសកម្មភាពកាត់បន្ថយគ្រោះមហន្តរាយក្នុងភូមិចំនួន១០នៅខេត្តស្វាយរៀងក្នុងខែមករា ឆ្នាំ ២០០៧ ។












# Flood Programme
# កម្មវិធីទឹកជំនន់

## Kratie

Located on the banks of the Mekong River, Kratie is a province that is affected by both seasonal flooding and flash floods on an annual basis. However, since the 2000 flooding, the floods each year have become more prolonged with the water levels higher.

Oxfam started working in Kratie initially in March 2006 and has supported the implementation of a Disaster Risk Reduction project based on the Takéo Model.

Working with Kratie Women's Welfare Association (KWWA), a welfare and gender capacity building organization, Oxfam has helped to provide boats, fishing nets, rain water catchment containers, and vegetable seeds in 19 villages.  We have also improved an existing safe area with infrastructires designed to provide safe water, human and livestock and sanitation facilities.

## ក្រចេះ

ដោយសារមានទីតាំងនៅតាមដងទន្លេមេគង្គ ក្រចេះគឺជាខេត្តមួយដែលត្រូវទទួលរងទាំងទឹកជំនន់តាមរដូវនិងទឹកជំនន់ខុសរដូវជារៀងរាល់ឆ្នាំ។ ទោះយ៉ាងនេះក្តី ចាប់តាំងពីទឹកជំនន់ឆ្នាំ២០០០មកទឹកជំនន់រាល់ឆ្នាំមានរយៈពេលវែងនិងមានកំរិតទឹកខ្ពស់ ។

អង្គការអុកស្វាមចាប់ធ្វើការដំបូងនៅខេត្តក្រចេះក្នុងខែមីនាឆ្នាំ ២០០៦ ហើយបានគាំទ្រឱ្យមានការអនុវត្តការងាររបស់គំរោង កាត់បន្ថយគ្រោះមហន្តរាយយកគំរូតាមគំរោងនៅខេត្តតាកែវ ។

សហការការងារជាមួយអង្គការសុខមាលភាពស្ត្រីខេត្តក្រចេះ (KWWA) ជាអង្គការកសាងសមត្ថភាពសុខមាលភាព និងយែនឌ័រ, អង្គការអុកស្វាមបានជួយទូក មងនេសាទ អាងតំកល់ទឹកភ្លៀង និងគ្រាប់ពូជបន្លែទៅភូមិចំនួន ១៩ ។ យើងបានធ្វើការកែលំអតំបន់ដែលមានសុវត្ថិភាពដោយមានរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធដើម្បីផ្តល់ទឹកស្អាតសំរាប់មនុស្សនិងសត្វចិញ្ចឹម និងសំភារៈបរិក្ខា អនាម័យ ។

## Future Plans
## ផែនការនាពេលខាងមុខ

Through the current Disaster Risk Reduction projects, Oxfam and its implementing partners directly responds to the needs of 20,000 vulnerable men, women and children living in Takéo, Kratie, Kompong Speu and Svay Rieng. Oxfam expects to have a positive influence on the lives of a further 200,000 people living in drought and flood prone areas through promoting a community-based approach to disaster preparedness and response using television, radio and print media.

ឆ្លងតាមរយៈគំរោងកាត់បន្ថយគ្រោះមហន្តរាយនាពេលបច្ចុប្បន្នអង្គការអុកស្វាមព្រមទាំងដៃគូអនុវត្តការងាររបស់ខ្លួនបានឆ្លើយតបផ្ទាល់ទៅនឹងតំរូវការចាំបាច់របស់បុរស ស្ត្រី និងកុមារងាយរងគ្រោះ ២០,០០០ នាក់ដែលរស់នៅក្នុងខេត្តតាកែវ ក្រចេះ កំពង់ស្ពឺ និងស្វាយរៀង ។ អង្គការអុកស្វាមសង្ឃឹមថានឹងធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមានទៅលើប្រជាជនប្រមាណ ២០០,០០០ នាក់ បន្ថែមទៀត ដែលកំពុងរស់នៅតាមតំបន់ងាយរងគ្រោះដោយទឹកជំនន់និងគ្រោះរាំងស្ងួត តាមរយៈការផ្សព្វផ្សាយវិធីសាស្ត្រដែលមានការចូលរួមពីសហគមន៍សំរាប់ការត្រៀមបង្ការគ្រោះមហន្តរាយ និងឆ្លើយតបតាមរយៈការប្រើទូរទស្សន៍ វិទ្យុ និងអត្ថបទសារព័ត៌មាន ។



# A Brief History of Oxfam International in Cambodia
## ប្រវត្តិសង្ខេបរបស់អង្គការអុកស្វាមអន្តរជាតិនៅកម្ពុជា

Oxfam International – a group of thirteen non-governmental agencies dedicated to fighting poverty and related injustice around the world – was one of the first international aid agency to work in Cambodia in 1979, after the genocidal Khmer Rouge regime.

Oxfam offices were opened in Phnom Penh in 1981. Supply of emergency aid gradually gave way to a programme of infrastructure rehabilitation, together with lobbying and advocacy work.

In 1992 the focus of Oxfam's work in Cambodia changed from technical assistance and support for government institutions to developing the capacity of local non-governmental organisations serving the needs of poor and marginalised communities in rural areas.

More than 65 partner organisations are currently supported by 8 Oxfam affiliates. They carry out a range of programmes from:

- Micro credit schemes
- Community based natural resource management
- Research and advocacy on land-right issues to support for civil and political rights
- Conflict resolution and campaigning against domestic violence
- Disaster Risk Reduction (DRR)

អង្គការអុកស្វាមអន្តរជាតិជាក្រុមមួយក្នុងចំណោមភ្នាក់ងារមិនមែនរដ្ឋាភិបាលចំនួន១៣ដែលបានប្តេជ្ញាប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនិងភាពអយុត្តិធម៌នៅជុំវិញពិភពលោក គឺជាភ្នាក់ងារផ្តល់ជំនួយអន្តរជាតិដំបូងគេមួយក្នុងចំណោមភ្នាក់ការទាំងឡាយដែលធ្វើការនៅប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧៩ បន្ទាប់ពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំ ។

ការិយាល័យអង្គការអុកស្វាមបានបើកដំណើរនៅទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៨១។ ការផ្តល់ជំនួយសង្គ្រោះបន្ទាន់បានផ្តល់ជាបន្តបន្ទាប់ទៅឱ្យគំរោងកម្មវិធីស្តារហេដ្ឋារចនាសម្ព័ន្ធរួមជាមួយការងារសំរបសំរួលនិងតស៊ូមតិ ។

ក្នុងឆ្នាំ ១៩៩២ ការងារចំបងរបស់អង្គការអុកស្វាមនៅប្រទេសកម្ពុជាបានប្តូរពីការផ្តល់ជំនួយផ្នែកបច្ចេកទេសនិងគាំទ្រដល់ស្ថាប័នរដ្ឋាភិបាលទៅជាអភិវឌ្ឍន៍សមត្ថភាពអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកវិញ ដែលបំរើសេចក្តីត្រូវការចាំបាច់ដល់សហគមន៍ក្រីក្រនិងសហគមន៍រងគ្រោះនៅតាមតំបន់ជនបទ ។

បច្ចុប្បន្ននេះមានអង្គការដៃគូច្រើនជាង៦៥អង្គការ បានទទួលការគាំទ្រជំនួយពីសាខាអង្គការអុកស្វាមចំនួន៨ ។ អង្គការទាំងនោះអនុវត្តសកម្មភាពលើកម្មវិធី:

- គំរោងឥណទានខ្នាតតូច
- ការគ្រប់គ្រងធនធានធម្មជាតិថ្នាក់សហគមន៍
- ស្រាវជ្រាវនិងតស៊ូមតិស្តីពីបញ្ហាសិទ្ធិដីធ្លីដើម្បីគាំទ្រសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ
- ដោះស្រាយទំនាស់និងធ្វើយុទ្ធនាការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ
- កាត់បន្ថយគ្រោះមហន្តរាយ (DRR)



# Oxfam affiliates and partners working in Damage Risk Reduction in Cambodia:

**OXFAM AMERICA**
East Asia Regional Office
3rd floor # 54, Street 108, Wat Phnom, Dau Penh, Phnom Penh
Tel: +855 23 210 357 , Fax: +855 23 223 119
Email: eastasia@oxfamamerica.org
Web site: www.oxfamamerica.org

**OXFAM AUSTRALIA**
House 68, Street 135, Tuol Tom Poung I,
Chamkarmorn, Phnom Penh
Tel: +855 23 211 570, Fax: +855 23 214 749
Email: caacam@online.com.kh
Web site: www.oxfam.org.au

**OXFAM GB**
House 442, Street 193, Sangkat Toul Svay Prey1, Khan Chamkarmon, Phnom Penh
Tel. +855 23 212 353 fax: +855 23 211 873
Email: phnompenh@oxfam.org.kh
Web site: www.oxfam.org.uk

**OXFAM HONG KONG**
House 68, Street 135, Tuol Tom Poung I,
Chamkarmorn, Phnom Penh
Tel: +855 23 211 570, Fax: +855 23 214 749
Email: benl@oxfam.org.hk
Web site: www.oxfam.org.hk

**OXFAM NOVIB** (Netherlands)
Mauritskade 9, Postbus 30919,
2500 GX, The Hague,
The Netherlands
Tel: +31 71 342 1621
Email: info@oxfamnovib.nl
Web site: www.oxfamnovib.nl

**CCK**
Chambork Em Village, Rominh Commune,
Koh Andeth Distirct, Takeo Province
Tel: +855 12 971 421

**NAPA**
House189, Street 182 (Tep Phon), Phsar Depo I, Phnom Penh
Tel: +855 16 838387

**KWWA**
Sresdao Village, Orussey Commune, Kratie
Tel: +855 72 971 586 Fax: +855 72 971586
Email: kwwakrt@camintel.com

**PADEK**
House 72, Street 360, Phnom Penh,
Tel: +855 23 362 779 Fax: +855 23 216 224
Email: padek@everyday.com.kh
Web site: www.padek.org

Oxfam
International